ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ១០៣/២៤ ប.ក

# របាយការណ៍ត្រីមាសទី១ ឆ្នាំ២០២៤
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តត្រីមាសទី២ ឆ្នាំ២០២៤

## I. ស្ថានភាពទូទៅ

សកលលោកបានប្រឈមនឹងវិបត្តិសាកលធំៗ ប្លែកៗ គួរឱ្យកត់សម្គាល់ រួមទាំងគ្រោះធម្មជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ជំងឺរាតត្បាត វិបត្តិខ្វះស្បៀងអាហារ សង្គ្រាមរ៉ាំរ៉ៃដែលបាន និងកំពុងគំរាមកំហែងដល់សន្តិសុខមនុស្សជាតិតាមបណ្តាប្រទេសដែលមានល្បឿនឧស្សាហកម្មជឿនលឿនមួយចំនួន បានជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមជាសកល គួរឲ្យព្រួយបារម្ភ ដែលវិបត្តិនេះ ក៏បានជះឥទ្ធិពលដល់បណ្តាប្រទេសនានា រួមទាំងកម្ពុជាផងដែរ។ ក្នុងស្ថានភាពដ៏លំបាកនេះ ប្រជាពលរដ្ឋ តាមបណ្តាប្រទេសនានា បានប្រឈមនឹងកង្វល់យ៉ាងធ្ងន់ធ្ងរនៃអសន្តិសុខ ក៏ដូចជាភាពស្មុគស្មាញក្នុងជីវភាពរស់នៅ ដែលជាឱកាសឲ្យក្រុមទុច្ចរិតបានប្រើគ្រប់មធ្យោបាយទាញយកផលចំណេញតាមរយៈការបង្កើតនូវបទល្មើសថ្មីៗ រួមទាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ ជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដ៏ទំនើប ទាក់ទាញមនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ស្ថានភាព ឲ្យរងគ្រោះ ក្នុងកលល្បិចដ៏ពិសពុល ដើម្បីបម្រើមហិច្ឆតាផលប្រយោជន៍ទុច្ចរិតរបស់ខ្លួនយ៉ាងសាហាវឃោរឃៅ។

រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧នៃរដ្ឋសភា និងបានបន្តការប្តេជ្ញាចិត្ត យកចិត្តទុកដាក់កាន់តែខ្លាំងលើកិច្ចការពារថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ សុខសុវត្ថិភាព និងសុខុមាលភាពសង្គមឱ្យកាន់តែរឹងមាំ ព្រមទាំងការធានានូវសិទ្ធិសេរីភាពស្របច្បាប់របស់ពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញនិងបទប្បញ្ញត្តិច្បាប់ជាធរមាន។ នៅក្នុងតំបន់ ព្រះរាជាណាចក្រកម្ពុជាបានរក្សាជំហរ ក្នុងការចូលរួមដោះស្រាយបញ្ហា ដោយទន់ភ្លន់ បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាព រឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ។

ជាការឆ្លើយតបចំពោះការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលក្នុងនោះ មុំទី១ បានផ្តោតលើការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឱ្យជីវជាថល។ ដើម្បីពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានកែសម្រួល និងបំពេញបន្ថែមសមាសភាពក្នុងរចនាសម្ព័ន្ធចាត់តាំងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៥ឆ្នាំបន្ត ពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០២៨ បន្ថែមទៀត។

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ជាសមាជិកនៃគណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត ដោយមានការចូលរួមគាំទ្រ និងសហការពីអង្គការដៃគូជាតិ និង

អន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម តាមយុទ្ធសាស្ត្រទាំងបួននៃផែនការ ក៏ដូចជាតាម ស្ថានភាពជាក់ស្តែង ទទួលបានលទ្ធផលដូចខាងក្រោម ៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការងារច្បាប់ គោលនយោបាយ សន្ធិសញ្ញា និងអនុស្សរណៈនៃការយោគយល់

- **ក្រសួងមហាផ្ទៃ៖** បានបន្តពិនិត្យពិភាក្សា លើសេចក្តីព្រាង អនុស្សរណៈ នៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត។
- **ក្រសួងយុត្តិធម៌៖**
  –បន្តពិនិត្យសេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" ចំនួន ០៣ច្បាប់ និង សន្ធិសញ្ញា ស្តីពី"**បត្យាប័ន**" ០៣ច្បាប់ រវាងព្រះរាជាណាចក្រកម្ពុជាជាមួយនឹង៖ (១) សាធារណរដ្ឋឥណ្ឌា (២) សាធារណរដ្ឋបេឡារុស និង (៣) សាធារណរដ្ឋតួកគី។
  –បន្តពិនិត្យសេចក្តីព្រាងសន្ធិសញ្ញា ស្តីពី «ការផ្ទេរទណ្ឌិត» ចំនួន០៥ច្បាប់ រវាងព្រះរាជាណាចក្រកម្ពុជាជាមួយនឹង៖ (១)សាធារណរដ្ឋប៉េរូ (២)សាធារណរដ្ឋកូរ៉េ (៣)សាធារណរដ្ឋតួកគី (៤)សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (៥)ព្រះរាជាណាចក្របែលហ្ស៊ិក។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖ បាន រៀបចំសេចក្តីព្រាង៖
  ១-ប្រកាស ស្តីពីលក្ខណៈ និងនីតិវិធីនៃការជ្រើសរើសកម្មករ និយោជិតវ័យក្មេងនៅតាមសហគ្រាស គ្រឹះស្ថានការងារ កម្ពុជានៅបរទេស»។
  ២-ប្រកាស ស្តីពីការហាមឃាត់កម្មករ និយោជិតវ័យក្មេងធ្វើការ នៅតាមសហគ្រាស គ្រឹះស្ថានផលិតផលនាំចេញ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** បានពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិបទដ្ឋាន(SOP) ស្តីពីការគ្រប់គ្រងករណី និងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទ្វេភាគីជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម។

#### ២. ការងារច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ ៖** បាន៖
  ១-សហការជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូ បិទបញ្ចប់នៃកិច្ចប្រជុំកម្រិតបច្ចេកទេស ពិនិត្យសេចក្តីព្រាងឯកសារ ស្តីពីទេសន្តរប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា។
  ២-ប្រជុំពិភាក្សា លើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ រវាង គ.ជ.ប.ជ និងអង្គការមូលនិធិអេ២១ ស្តីពីកិច្ចសហប្រតិបត្តិការលើការងារបង្ការ ទប់ស្កាត់ និងកំណត់អត្តសញ្ញាណបឋម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស សម្រាប់អនុវត្តក្នុងឆ្នាំ ២០២៤-២០២៦ ។
  ៣.ប្រជុំពិភាក្សាជាមួយក្រុមបច្ចេកទេស ដើម្បីពិនិត្យ និងរៀបចំកែសម្រួលសៀវភៅគោលបង្រៀនសម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីគោលការណ៍ណែនាំស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** បានពិនិត្យ និងកែសម្រួលលើគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បាន៖
  ១-សិក្សា ពិនិត្យកែសម្រួលខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអន្តោប្រវេសន៍ថ្មីឱ្យកាន់តែប្រសើរ និងកែសម្រួលអនុក្រឹត្យលេខ ១២៣អនក្រ.បក ស្តីពីបែបបទសម្រាប់អនុញ្ញាតចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ឱ្យបានឆ្លើយតបចំពោះសំណូមពរនៃសករាជថ្មី។

២-ពិនិត្យកែសម្រួលលើសេចក្តីព្រាងអនុក្រឹត្យលេខ ៦៤អនក្រ.បក ចុះថ្ងៃទ ០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រទូទាំងព្រះរាជាណាចក្រកម្ពុជា។

៣-ពិនិត្យកែសម្រួលខ្លឹមសារប្រកាសលេខ ៣៥០៨ប្រ.ក ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ជូនចេញ ការបណ្តេញចេញ និងការកំណត់ចិរវេលាហាមឃាត់ការចូលចំពោះជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា។

៤-បង្កើតនូវគំរូបង្ហាន់ដៃ ស្តីពីការផាកពិន័យអន្តរការ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ ស្តីពីអន្តោប្រវេសន៍ សម្រាប់មន្ត្រីអន្តោប្រវេសន៍យកទៅប្រើប្រាស់។

### ៣. ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានកិច្ចសហប្រតិបត្តិការបានជំនួបពិភាក្សាការងារជាមួយ៖ ១-គណៈប្រតិភូអង្គការ សហប្រជាជាតិ មានឯកឧត្តម Joseph Scheuer តំណាង អង្គការសហប្រជាជាតិប្រចាំកម្ពុជា លោកស្រី Roueida El Hage តំណាងឧត្តមស្នងការសិទ្ធិមនុស្ស OHCHR នៅកម្ពុជា លោកស្រី Alissa Chaker តំណាងអង្គការ UNDP ប្រចាំកម្ពុជា លោកស្រី Kristin Parco ប្រធានបេសកកម្មអង្គការ IOM កម្ពុជា ស្តីពីការពង្រឹងកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ២-តំណាងអង្គការ អាស៊ានអាក់ ក្នុងគោលបំណងធ្វើបទបង្ហាញ ស្តីពីផែនការសកម្មភាពការងាររបស់អង្គការអាស៊ានអាក់ ក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ៣-តំណាងពីអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ក្នុងការរៀបចំសេចក្តីព្រាងផែនការជាតិសម្រាប់អនុវត្ត កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ ៤-តំណាងអង្គការ IJM ក្នុងការរៀបចំផែនការបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធី នៃកាកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របសម្រាប់ខេត្តកោះកុង បាត់ដំបង និងបន្ទាយមានជ័យ។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានដឹកនាំក្រុមការងារបច្ចេកទេសធ្វើកិច្ចសហប្រតិបត្តិការជំនួបពិភាក្សាការងារ៖ ១-ពិនិត្យ និងផ្តល់យោបល់លើឯកសារគម្រោងរបស់អង្គការ ILO ស្តីពីការងារសមរម្យប្រចាំប្រទេសកម្ពុជាឆ្នាំ២០២៤-២០២៨ (DWCP) , ២-ស្តីពីការរៀបចំផែនការសកម្មភាព ក្រោមគម្រោង GIZ Fabric II នៃអនុស្សរណៈយោគយល់គ្នារវាងក្រសួង និងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ប្រចាំកម្ពុជា ស្តីពីការអនុវត្តកម្មវិធីគម្រោងពង្រឹងនិរន្តរភាពវិស័យវាយនភណ្ឌ និងកាត់ដេរនៅទ្វីបអាស៊ីដំណាក់កាលទី២ នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣-២០២៥, ៣-ស្តីពីការធ្វើដំណើរការចុះត្រួតពិនិត្យលក្ខខណ្ឌការងាររួមគ្នា និងជំនាញក្នុងការសរសេររបាយការណ៍ជាមួយ ILO-BFC, ៤-ជាមួយអង្គការ IOM ដើម្បីពិភាក្សាលើដំណើរការរៀបចំផែនការ សកម្មភាពរួមកម្ពុជា-ថៃ សម្រាប់អនុវត្ត MOU រវាងកម្ពុជា និងថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ, ៥-ទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ដើម្បីពិនិត្យនឹងពិភាក្សាលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិបទដ្ឋាន (SOP) ស្តីពីការគ្រប់គ្រងករណី និងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តសៀមរាប។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** បានជួបពិភាក្សាកិច្ចប្រជុំទ្វេភាគីជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិបទដ្ឋាន(SOP) ស្តីពីការគ្រប់គ្រងករណី និងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## ខ. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១. ការផ្សព្វផ្សាយដោយផ្ទាល់

ត្រីមាសទី១ ឆ្នាំ២០២៤ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូបានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋ តាមរយៈវេទិកាសាធារណៈ ការ

អនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" និងតាមកម្មវិធីផ្សេងៗ សរុបចំនួន **៤៨.០២៧**លើក មានអ្នកចូលរួមសរុបចំនួន **២.២៩៧.៥១៧**នាក់ (ស្ត្រី **១.២២៣.០៥៤**នាក់) (ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២៣ មានចំនួន **៥៣.៦៨០**នាក់) គឺមានការកើនឡើងចំនួន **២.២៤៣.៨៣៧**នាក់ ស្មើនឹង **៩៧,៦៦%** ដូចមានក្នុងតារាង ខាងក្រោម៖

***តារាងទិន្នន័យការផ្សព្វផ្សាយផ្ទាល់***

| ការផ្សព្វផ្សាយផ្ទាល់ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| តាមរយៈភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និង វេទិកាផ្សព្វផ្សាយសាធារណៈ | ៤៧.៨០០ | ២.២៧៧.៥៣៤ | ១.២០៥.០៧៦ |
| តាមរយៈកម្មវិធីផ្សេងៗ (ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ) | ៨៥ | ៧.៤៦៤ | ៣.៤២៩ |
| អង្គការដៃគូ | ១៤២ | ១២.៩៥៨ | ១៤.៥៤៩ |
| **សរុប** | **៤៨.០២៧** | **២.២៩៧.៥១៧** | **១.២២៣.០៥៤** |

### ១.១.១. ការផ្សព្វផ្សាយតាមរយៈភូមិឃុំ-សង្កាត់មានសុវត្ថិភាព- និងវេទិកាសាធារណៈ

ត្រីមាសទី១ ឆ្នាំ២០២៤ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូមួយចំនួន បានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋ រួមគ្នា និងដោយឡែកពីគ្នា តាមរយៈវេទិកាសាធារណៈ ស្ដីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព អំពើជួញដូរមនុស្ស និងតាមការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" សរុបចំនួន **៤៧.៨០០**លើក មានអ្នកចូលរួមសរុបចំនួន **២.២៧៧.៥៣៤**នាក់ ស្ត្រីចំនួន **១.២០៥.០៧៦**នាក់ (ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២៣ មានចំនួន **៥០.៥៥៨**នាក់ គឺមានការកើនឡើងចំនួន **២.២២៦.៩៧៦**នាក់ ស្មើនឹង **៩៧,៧៨%**) ដូចមានក្នុងតារាងខាងក្រោម៖

**តារាងទិន្នន័យផ្សព្វផ្សាយតាមរយៈភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | ក្រសួងអភិវឌ្ឍន៍ជនបទ | ០៣ | ៦៩៦ | ៣៨៥ | | | |
| ២ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣.០៦៨ | ២០៦.៧៧៦ | ១០៤.០៣៤ | ១.៦០៤ | ៦៩.៥៦៧ | ១៦.២២៥ |
| ៣ | កាកបាទក្រហមកម្ពុជា | ០៨ | ១.៥៩០ | ៥៧៤ | | | |
| | សរុប ក្រសួង ស្ថាប័ន | ៣.០៧៩លើក | ២០៩.០៦២នាក់ | ១០៤.៩៩៣នាក់ | ១.៦០៤នាក់ | ៦៩.៥៦៧នាក់ | ១៦.២២៥នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | ៤៣ | ១០.០៧១ | ៧.៤៧២ |
| ២ | ខេត្តកណ្ដាល | ៤.៤៨៣ | ៣៣៨.៥២៥ | ១៦៩.៣១២ | ៧.៤៩៩ | ១៥៩.៩១៩ | ៨១.៩០៧ |
| ៣ | ខេត្តបាត់ដំបង | ២.៧៧៥ | ១៤៤.៧៥០ | ៧៥.០៨៣ | ២.១០១ | ៧០.៨៣៤ | ៣៨.៨០៤ |
| ៤ | ខេត្តពោធិ៍សាត់ | ១.០០៤ | ៧៥.១១៤ | ៤១.០៣២ | ៥៥២ | ២២.៩៤៩ | ១០.៩៧៥ |
| ៥ | ខេត្តសៀមរាប | ១.៤៣០ | ១១០.៤០៦ | ៦៦.៧០៥ | ៥៧០ | ១៧.៨៥៤ | ១២.៣៦៥ |
| ៦ | ខេត្តកំពង់ឆ្នាំង | ២.១០៩ | ៦៥.៣៥៧ | ៣៤.១៤០ | ១.០៧៩ | ២៦.២៣២ | ១៦.៤៤៩ |
| ៧ | ខេត្តកំពង់ចាម | ៥.៤០៦ | ៣២១.៥១១ | ១៦២.៦៣៦ | ៥ | ៣១៧ | ១០៤ |
| ៨ | ខេត្តព្រះសីហនុ | ៣១១ | ១៥.១៤៩ | ៨.១៤៨ | ៦ | ៣៥៦ | ១៨៤ |
| ៩ | ខេត្តព្រះវិហារ | ៣៤ | ៣.៩៨៩ | ២.៣២៧ | | | |
| ១០ | ខេត្តស្វាយរៀង | ១.០៥០ | ៦៣.៥៣១ | ៥៣.៥៦៥ | ៨៨៥ | ៣៣.៨២២ | ១៩.៥៥៦ |
| ១១ | ខេត្តប៉ៃលិន | ៧២ | ៦.៨៧៦ | ៣.១៨៧ | ៤៦៤ | ៧.៦០៤ | ២.៥៦០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២ | ខេត្តកោះកុង | ៦៦៦ | ១៨.៥៥០ | ៩.១៦៩ | ៤១៣ | ៩.៧១៧ | ៤.៣៨៨ |
| ១៣ | ខេត្តកំពត | ១៣៦ | ២.៤១៧ | ១.៣៧៥ | ៣០ | ១.១២០ | ៧០០ |
| ១៤ | ខេត្តកំពង់ធំ | ៨៣៧ | ៧៤.១២៧ | ៥១.១២១ | ៣០៨ | ១៥.០៦៦ | ៨.៧៣៥ |
| ១៥ | ខេត្តតាកែវ | ១.៥០៨ | ៧០.៨១៧ | ៣០.៣២០ | ៣២៨ | ១០.២៦៣ | ៥.៧០៤ |
| ១៦ | ខេត្តក្រចេះ | ៥៩ | ៣.៧៥២ | ១.៩០៣ | ០០ | ០០ | ០០ |
| ១៧ | ខេត្តកែប | ៥៧ | ១០.៦៧៣ | ៥.៤៩០ | ៩០ | ៣.៨៨៩ | ១.៩៧៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៧ | ៧.៧៧៤ | ៤.១៣៩ | ០០ | ០០ | ០០ |
| ១៩ | ខេត្តស្ទឹងត្រែង | ១០ | ៦៩៣ | ៤៤៦ | ០០ | ០០ | ០០ |
| ២០ | ខេត្តរតនគិរី | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| ២១ | ខេត្តព្រៃវែង | ១.៧២៥ | ១៤៥.៥៥៥ | ៧៥.៦៨៤ | ៥៣៩ | ១២.៣៣៣ | ៩.៥៩២ |
| ២២ | ខេត្តត្បូងឃ្មុំ | ៤១៣ | ៨.២២៧ | ៤.៥៧៧ | ១១ | ៣៦៩ | ១៣៦ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ២.៤៤១ | ៣៩.៧២១ | ២៣.០៩១ | ៥៨៦ | ១៦.៨៨៦ | ១០.០៣២ |
| ២៤ | ខេត្តឧត្តរមានជ័យ | ៥៩៨ | ៣៥.៧៥៧ | ២០.៦៣១ | ១០៤ | ៤.០៨៩ | ២.៥១៦ |
| ២៥ | ខេត្តមណ្ឌលគិរី | ៣៤៩ | ១១.១៣៦ | ៥.២៤១ | ២៤ | ៨០៨ | ៣៨៤ |
| សរុប រាជធានី-ខេត្ត | | ២៧.៤៨០ | ១.៥៧៤.៤០៧ | ៨៤៩.៣២២ | ១៥.៦៣៧ | ៤២៤.៤៩៨ | ២៣៤.៥៣៦ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ៤៧.៨០០លើក | | ២.២៧៧.៥៣៤នាក់ | | ១.២០៥.០៧៦នាក់ | |

### ១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) សហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធបានផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើជួញដូរតាមរយៈ៖ **១-**ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០២៣ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធាន គ.ជ.ប.ជ។** **២-**សិស្សានុសិស្សនៅក្នុងពេលគោរពទង់ជាតិមុនចូលរៀន និងនៅក្នុងមេរៀនសាលាផងដែរ។ **៣-**ក្នុងពិធីចែកប័ណ្ណសរសើរដល់សិស្សឆ្នើមប្រចាំឆ្នាំសិក្សា២០២២-២០២៣ ។ **៤-**ក្នុងកិច្ចប្រជុំ កែសម្រួលអនុក្រឹត្យលេខ ៨៨អនក្រ.បក ស្តីពី ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ។ ក្នុងពិធីសន្និបាតបូកសរុបវាយតម្លៃការងារ អប់រំ យុវជន និងកីឡា ឆ្នាំ២០២២-២០២៣។ **៥-**ចុះអធិការកិច្ចពិសេសនៅក្រុមហ៊ុន រោងចក្រ សហគ្រាស។ **៦-**ចុះពិនិត្យ និងផ្សព្វផ្សាយវិស័យសិល្បៈភាពយន្ត ដើម្បីយល់ដឹងអំពីវប្បធម៌ សីលធម៌សង្គម។ **៧-**កម្មពិធីអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៦ ឆ្នាំ២០២៤។ **៨-**សម្តែងធម៌ទេសនាអប់រំអំពីតួនាទី កូនល្អ សិស្សល្អ មិត្តល្អ និងគុណមាតាបិតា។ សរុបចំនួន **២២៧**លើក មានអ្នកចូលរួមចំនួន **២០.៤២២**នាក់ ក្នុងនោះមានស្ត្រី **១៤.៥៤៩**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | អ្នកចូលរួម | ស្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | ០១ | ៣៩២ | ១៥៨ |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១៨ | ៣.០៧៥ | ១.៦១៤ |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបាត់ដំបង | ២៤ | ២៨១ | ១៧៨ |
| ខេត្តប៉ៃលិន | ០៣ | ៦៥០ | ៤៧០ |

| | | | |
|---|---|---|---|
| ខេត្តសៀមរាប | ០៧ | ១.០៩៤ | ៣៣៧ |
| ខេត្តកំពង់ចាម | ០៧ | ១៧៥ | ៨៦ |
| ខេត្តត្បូងឃ្មុំ | ០១ | ៦៤ | ១៣ |
| ខេត្តកណ្ដាល | ០៨ | ៦៨៣ | ២១៥ |
| ខេត្តតេនគិរី | ០២ | ៣៥៧ | ១៥០ |
| ខេត្តតាកែវ | ០១ | ៤៩៣ | ១២០ |
| ខេត្តកំពង់ឆ្នាំង | ១៣ | ២០០ | ៨៨ |
| **សរុប** | **៨៥នាក់** | **៧.៤៦៤នាក់** | **៣.៤២៩នាក់** |
| **អង្គការដៃគូ** | | | |
| អង្គការតំណក់ទឹក(ខេត្តបន្ទាយមានជ័យ) | ០២ | ៩៨ | ៥៦ |
| អង្គការអន្តរ(IOM)(ខេត្តបន្ទាយមានជ័យ) | ១២ | ៣៤០ | ១៣០ |
| អង្គការសាម៉ារីតាន់ភីស (ខេត្តបន្ទាយមានជ័យ) | ៧៥ | ២,១៥៤ | ៧២៤ |
| អង្គការការីតាសស្វីស (ខេត្តបាត់ដំបង) | ១៩ | ១.៤២២ | ៥៧០ |
| អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប) | ៣៣ | ៨.៨១៧ | ៤.៣៣៤ |
| អង្គការសម្ព័ន្ធចាប់ដៃ (ខេត្តត្បូងឃ្មុំ) | ០១ | ១២៧ | ៧៩ |
| **សរុប** | **១៤២** | **១២.៩៥៨** | **៥.៨៩៣** |
| **សរុបរួម** | **២២៧នាក់** | **២០.៤២២នាក់** | **១៤.៥៤៩នាក់** |

### ១.១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

▪ **អគ្គលេខាធិការ គ.ជ.ប.ជ៖** ១-ប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ "ជីវិតយើង សង្គមយើង" ដោយពិភាក្សាលើប្រធានបទ ស្ដីពី " រួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ" នៅក្នុងកម្មវិធីវិទ្យុជាតិ និងវិទ្យុវត្តភ្នំ ព្រមទាំងអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមសាកសួរ និងពិភាក្សាតាមរយៈទូរស័ព្ទផងដែរ។

▪ **ខេត្តកំពង់ចាម៖** ក-ក្រុមការងារជំនាញនៃ គ.ខ.ប.ជ បានចូលរួមធ្វើជាវាគ្មិននៅវិទ្យុ ក្រោមប្រធានបទការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប និងប្រសិទ្ធភាពនៃការទប់ស្កាត់ចំណាកស្រុកខុសច្បាប់ ចំនួន **០៤**លើក។ **ខ**-តំណាងស្នងការនគរបាលខេត្ត បានចូលរួមជាវាគ្មិននៅវិទ្យុ **០២**លើក៖ ១-ស្ដីពីការទប់ស្កាត់ភាពមិនប្រក្រតី របស់យុវជនក្នុងទិវាបុណ្យនៃក្ដីស្រឡាញ់។ ២-ប្រសិទ្ធភាពនៃការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់។

▪ **ខេត្តព្រៃវែង៖** តំណាងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមន្ទីរកិច្ចការនារីខេត្ត បានចូលរួមជាវាគ្មិនធ្វើបទបង្ហាញចែករំលែកចំណេះដឹង និងបទពិសោធន៍ ស្ដីពីស្ថានភាពទូទៅនៃការធ្វើចំណាកស្រុករបស់ពលករទេសន្តរប្រវេសន៍ និងយន្តការនៃការដាក់ពាក្យបណ្ដឹង ដែលមានអ្នកចូលរួមចំនួន **៦០**នាក់ (ស្រី **២៩**នាក់)។

▪ **ខេត្តបាត់ដំបង៖** តំណាងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនកិត្តិយសនៅស្ថានីយវិទ្យុជាតិកម្ពុជា ក្រោមប្រធានបទ **"សុវត្ថិភាពស្ត្រីក្នុងការធ្វើចំណាកស្រុក"** ០១លើក។

### ១.១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

▪ **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត មន្ទីរ-អង្គភាពពាក់ព័ន្ធ អាជ្ញាធរក្រុង-ស្រុក និងអង្គការដៃគូរដ្ឋបាលស្រុកពួក បានចែកខិត្តប័ណ្ណ បានផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន **២៩.៣៨៣**សន្លឹក និងបានសហការជាមួយអង្គការមូលនិធិអេ២១ រៀបចំកម្មវិធីចាក់បញ្ចាំងខ្សែវីដេអូ **"តើអ្នកអាចឃើញខ្ញុំទេ"** បានចំនួន **០១លើក** ដែលមានអ្នកចូលរួមសរុប **១៧៥នាក់** ស្រី **១១៦**នាក់។

▪ **ខេត្តបន្ទាយមានជ័យ៖** បានសហការជាមួយអង្គការបានផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសុវត្ថិភាពទេសន្តរប្រវេសន៍ តាមរយៈចែកប័ណ្ណ ដូចមាន៖ **១**-លេខាធិការដ្ឋាន គ.ខ.ប.ជ ចងបដាពាក្យស្លោក ៦ផ្ទាំង។ **២**-មណ្ឌលកំរៀងបានចែកខិត្តប័ណ្ណចំនួន **១.៣៤៧** មានអ្នកចូលរួម **១.៣៤៧**នាក់ ស្រី **៦៣៦**នាក់។ **៣**-អង្គការសាម៉ារីតាន់ភឺស (Samaritan Purse) បានចែកខិត្តប័ណ្ណ ដល់ពលករត្រឡប់ពីក្រៅប្រទេសចំនួន **២.២២០**នាក់ ស្រី **៨៧២**នាក់ កុមារ**២៤**នាក់។ **៤**-អង្គការតំណក់ទឹក បានចុះធ្វើបណ្ណាល័យចល័ត ដល់សិស្សានុសិស្ស និងកុមារតូច ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព មានអ្នកចូលរួម **២៦៧**នាក់ ស្រី **១២៨**នាក់។

▪ **ខេត្តឧត្តរមានជ័យ៖** មន្ទីរអប់រំយុវជន និងកីឡាខេត្ត បានផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស តាមរយៈការចែកខិត្តប័ណ្ណ **១.៣២៧**សន្លឹក។

▪ **ខេត្តបាត់ដំបង៖** អង្គការសាម៉ារីតាន់ភឺស បានចែកខិត្តប័ណ្ណផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព កិច្ចការពារការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ ចំនួន **៣.១១១**សន្លឹក, ចែកអាវយឺតចំនួន **២៨៣**នាក់ (ស្រី **៨៨**នាក់) និងបានសហការជាមួយក្រុមយុវជន និងយុវនារី ធ្វើយុទ្ធនាការសម្តែងរឿងអប់រំខ្លីៗ ស្តីពីការចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់ជួញដូរមនុស្ស មានអ្នកចូលរួមសរុបចំនួន **២០០**នាក់។

▪ **ខេត្តតាកែវ៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សហការជាមួយអាជ្ញាធរ អង្គការដៃគូ បានផ្សព្វផ្សាយអប់រំ តាមរយៈពាក្យស្លោក ស្តីពីអំពើហិង្សា ការជួញដូរផ្លូវភេទកុមារចំនួន **១៤០**សន្លឹក ស្មើ **៥០**សាលា និងតាមថ្នាក់រៀនបានចំនួន **២៥០**ពាក្យស្លោក និងបដាចំនួន **៨០**សន្លឹក ស្មើ **៥០**សាលា។

### **១.២. ការផ្សព្វផ្សាយអប់រំដោយប្រយោល**

#### **១.២.១. ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ(វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក)**

▪ **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ៖** ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈគេហទំព័រហ្វេសប៊ុក មានការទស្សនាចំនួន **៣.៤១៦**ដង។

▪ **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារក្នុងស្រុកជាជាងការចំណាកស្រុកដោយប្រថុយប្រថាន ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ចំនួនបានចំនួន **៥៨៥**លើក ក្នុងនោះបានធ្វើការផ្សាយផ្ទាល់ ចំនួន **១៧៧**លើក ចាក់ផ្សាយឡើងវិញ ចំនួន **៤០៨**លើក។

▪ **ខេត្តប៉ៃលិន៖** បានផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈវិទ្យុ និងទូរទស្សន៍ចំនួន **៥៧៦**លើក។

▪ **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយសារអប់រំតាមវិទ្យុបាវយណ៍អណ្តែត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១០០**លើក។

▪ **ខេត្តត្បូងឃ្មុំ៖** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយតាមវិទ្យុជាតិត្បូងឃ្មុំ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន **១៨០**លើក។

## **២. ការបង្ការទប់ស្កាត់តាមវិធានការជំនាញ**

### **២.១. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់**

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលចំនួន **០៣**ខេត្ត បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងវៀតណាមចំនួន **៣៣**លើក មនុស្សចំនួន **៤៨០**នាក់ (ស្រី **១៦៣**នាក់ កុមារ **០១**នាក់) បានធ្វើកិច្ចសន្យាការអប់រំណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យ ចំនួន **៣០**លើក មនុស្សចំនួន **៤៧១**នាក់ (ស្រី **១៦០**នាក់)។
- ខេត្តបាត់ដំបង ចំនួន **០២**លើក មនុស្សចំនួន **០៤**នាក់ (ស្រី **០១**នាក់ កុមារ **០១**នាក់)។

- ខេត្តព្រះវិហារ ចំនួន ០១លើក មនុស្សចំនួន ០៥នាក់ (ស្រី ០២នាក់)

២.៣. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

២.៣.១. ការគ្រប់គ្រងស្ថិតិពលករខ្មែរ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** យោងតាមតាមរបាយការណ៍ ត្រីមាសទី១ ឆ្នាំ២០២៤នេះ ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System(EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប **១១.៩៣៣**នាក់(ស្រី **៤.៧៣២**នាក់) ក្នុងនោះមាន៖

- ប្រទេសថៃ ចំនួន **៨.០៤៧**នាក់ (ស្រី **៣.៥៥៩**នាក់)
- សាធារណរដ្ឋកូរ៉េ ចំនួន **២.៣៩៤**នាក់ (ស្រី **៤៧១**នាក់)
- ប្រទេសជប៉ុន ចំនួន **១.៤១៨**នាក់ (ស្រី **៦២៨**នាក់)
- ប្រទេសសិង្ហបុរី ចំនួន **១៤**នាក់ (ស្រី **១៤**នាក់)
- តំបន់រដ្ឋបាលពិសេសហុងកុង ចំនួន **២៥**នាក់ (ស្រី **២៥**នាក់)។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖**

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្តទាំង ២៥** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរ ចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងជាប់ការទាក់ទងសរុបចំនួន **១៩៣.៩៥៨**នាក់ (ស្រី**៨៥.៨១២**នាក់) អនីតិជន **៣.១៣៨**នាក់(ស្រី **១.១៥១**នាក់)៖
  - ស្របច្បាប់ ចំនួន **១៥១.២៧២**នាក់ (ស្រី **៦៨.៩៥៥**នាក់) អនីតិជន **៤២៦**នាក់ (ស្រី **១៥៦**នាក់)
  - មិនស្របច្បាប់ចំនួន **៤២.០២១**នាក់(ស្រី**១៦.៥៧២**នាក់) អនីតិជន **២.៥៨២**នាក់(ស្រី **៩៦០**នាក់)
  - ជាប់ការទាក់ទងចំនួន **៦៦៥**នាក់(ស្រី **២៨៥**នាក់) អនីតិជន **១៣០**នាក់(ស្រី**៣៥**នាក់)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១៩.១៧៩**នាក់ (ស្រី **៧.៩២៩**នាក់) អនីតិជន **២៦០**នាក់(ស្រី **៩៤**នាក់)។

២.៤. ការគ្រប់គ្រងស្ថិតិជនបរទេស បច្ចុប្បន្នភាពចំណូលស្រុក

▪ អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖

១-ការគ្រប់គ្រងស្ថិតិជនបរទេសចូលមកកម្ពុជាស្របច្បាប់

*ក-គ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត* ក្នុងត្រីមាសទី១ ឆ្នាំ២០២៤នេះ អគ្គនាយកដ្ឋានបានទទួលពាក្យ និងចេញប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនអន្តោប្រវេសន្តពីស្នងការដ្ឋាននគរបាលចំនួន ១២ រាជធានី-ខេត្ត សរុបចំនួន **១.៥៦៤**ច្បាប់ (ស្រី **៧៣៧**នាក់) ក្នុងនោះស្នើសុំប័ណ្ណលើកដំបូងចំនួន **១៣០**ច្បាប់(ស្រី **៥៨**នាក់) បន្តលើកទី១ចំនួន **២១៤**ច្បាប់(ស្រី **៩៤**នាក់) បន្តលើកទី២ចំនួន **៩០៣**ច្បាប់(ស្រី **៤៣០**នាក់) បន្តលើកទី៣ចំនួន **២៨៣**ច្បាប់(ស្រី **១៣៧**នាក់) បន្តលើកទី៤ ចំនួន **៣២**ច្បាប់(ស្រី **១៧**នាក់), ទុតិយតាលើកទី១ ចំនួន **០១**ច្បាប់ និងទុតិយតាលើកទី២ ចំនួន **០១**ច្បាប់(ស្រី **០០**នាក់)។

<u>កត់សម្គាល់</u>៖ បានប្រគល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជូនទៅស្នងការដ្ឋាននគរបាលចំនួន រាជធានី-ខេត្ត សរុបចំនួន **១២៣.៥២១**ប័ណ្ណ (ស្រី **៦៥.៤៣០**នាក់) ក្នុងនោះ៖ ស្នើសុំលើកដំបូង ចំនួន **៦៨.៨៣៥**ប័ណ្ណ(ស្រី **៣២.៩៥៤**នាក់), បន្តសុពលភាពលើកទី១ ចំនួន **៥១.៤១៦**ប័ណ្ណ(ស្រី **២៣.៩១៥**នាក់), បន្តលើកទី២ ចំនួន **១៥.៣៤៣**ប័ណ្ណ(ស្រី **៧.១៨៥**នាក់), បន្តលើកទី៣ ចំនួន **២.៨៤៦**ប័ណ្ណ(ស្រី **១.៣៣៧**នាក់) ,បន្តលើកទី៤ ចំនួន **៧៥**ប័ណ្ណ(ស្រី **៣៦**នាក់) និងបន្តលើកទី៥ ចំនួន **០៦**ប័ណ្ណ (ស្រី **០៣**នាក់)។

**ខ-គ្រប់គ្រងជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន និងហត្ថពលករបរទេស** តាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា (CDC) គិតត្រឹមខែមីនា ឆ្នាំ២០២៣ ក្រុមហ៊ុនវិនិយោគបរទេសដែលបានចុះបញ្ជីចំនួនសរុប ៣.២០៨ក្រុមហ៊ុន មាន៤៤សញ្ជាតិ ប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០២៣ កើនឡើងចំនួន **៦៩**ក្រុមហ៊ុន

ស្មើនឹង ២,១៨% រួមមាន៖ វិស័យកសិកម្មចំនួន **២៥៨**ក្រុមហ៊ុន មាន**១៩**សញ្ជាតិ វិស័យទេសចរណ៍ចំនួន **១២៦**ក្រុមហ៊ុន មាន **១៧**សញ្ជាតិ វិស័យហេដ្ឋារចនាសម្ព័ន្ធចំនួន **១៦២**ក្រុមហ៊ុន មាន**១៧**សញ្ជាតិ និងវិស័យរោងចក្រសហគ្រាសចំនួន **២.៦៦២**ក្រុមហ៊ុន មាន **៤០**សញ្ជាតិ ដោយមានទុនវិនិយោគសរុបចំនួន **៤៤.៦០៩.៨៩០.១៩៤**ដុល្លារ និងផ្តល់ការងារដល់ពលករបរទេស-ខ្មែរ សរុប **៣.១៦២.៧៥៣**កន្លែង។ ប្រទេសដែលមកដាក់ទុន វិនិយោគច្រើនជាងគេមានដូចជា៖ ប្រទេសចិន, កូរ៉េខាងត្បូង, សឹង្ហបូរី និងម៉ាឡេស៊ី។

**គ-ការគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្ត និងបច្ចេកវិទ្យា** ដើម្បីធានាដល់ការគ្រប់គ្រងវត្តមានជនបរទេសឱ្យកាន់តែមានប្រសិទ្ធភាព និងទទួលបាននូវប្រសិទ្ធផលស្របតាមផែនការ និងទិសដៅការងារកំណត់ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់តាំងអនុវត្តសេចក្តីណែនាំលេខ **០២៨ ស.ណ.ន** របស់ក្រសួងមហាផ្ទៃ ស្តីពីការរាយការណ៍វត្តមានស្នាក់នៅរបស់ជនបរទេសតាមមូលដ្ឋាន ដោយបានខិតខំប្រឹងប្រែងរៀបចំប្រមូលផ្តុំវិធានការ ឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការពិនិត្យស្នើឱ្យបំពេញអាសយដ្ឋានច្បាស់លាស់នៅក្នុងសលាកបត្រពេលមកដល់ ការពង្រឹងសំណុំឯកសារ បែបបទពេលមកស្នើសុំបន្តទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន និងរៀបចំប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ជនបរទេសដោយក្នុងនោះបានផ្តល់ទិដ្ឋាការ៖ ១-ចូលប្រទេសពេលមកដល់ចំនួន **៤១៤.៨៨៩**នាក់(ក្នុងនោះទិដ្ឋាការពិសេសប្រភេទ K ចំនួន **១០.៨៨៥**នាក់ ជូនពលរដ្ឋខ្មែរដែលកាន់លិខិតឆ្លងដែនបរទេស) និងផ្តល់ទិដ្ឋាការចូលតាមប្រព័ន្ធអេឡិចត្រូនិក (e_Visa) ចំនួន **១១.១៣១**នាក់។ ២-បានផ្តល់ទិដ្ឋាការចេញចំនួន **១.៣៥៦**នាក់ (ក្នុងនោះ ទិដ្ឋាការពិសេសប្រភេទ K ចំនួន **១៧៨**នាក់ជូនពលរដ្ឋខ្មែរដែលកាន់លិខិតឆ្លងដែនបរទេស)។ **៣**-បានផ្តល់ទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះ អាសន្នចំនួន **១៦៤.០៥៣**នាក់។

ដោយឡែក ចំពោះអ្នកស្នាក់នៅហួសរយៈពេលកំណត់ក្នុងត្រីមាស ឆ្នាំ២០២៣នេះ មានចំនួន **៧២៦**នាក់ មាន **៣៩**សញ្ជាតិ បានធ្វើការផាកពិន័យសរុបជាទឹកប្រាក់ចំនួន **៩៧.០៩០**ដុល្លារ សម្រាប់បង់ចូលថវិកាជាតិ។

ចំពោះការងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អគ្គនាយកដ្ឋានបានម្ចាស់ការកសាងដោយជោគជ័យលើការងារគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហៅកាត់ថា (FPC)និងបានដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។ ជាលទ្ធផលក្នុងត្រីមាសទី១ ឆ្នាំ២០២៣នេះ ជនបរទេសបានរាយការណ៍ពីវត្តមានស្នាក់នៅព្រះរាជាណាចក្រកម្ពុជានៅក្នុងប្រព័ន្ធ សរុបចំនួន **២៤៥.៦១៦**នាក់(ស្រី **៦៤.០៨៥**នាក់)។

**២-ការគ្រប់គ្រងស្ថិតិជនបរទេសខុសច្បាប់ និងការបង្ក្រាបបទល្មើស៖** មន្រ្តីនគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិ រកឃើញអ្នកដំណើរមិនប្រក្រតី មានបទល្មើសសរុបចំនួន **៩៧៣**លើក ជនល្មើសចំនួន **១.៧១០**នាក់ ក្នុងនោះ៖

- **បទល្មើសអន្តោប្រវេសន៍** សរុបចំនួន ៨៩១លើក ជនល្មើសចំនួន១.៣៦១នាក់ រួមមានបទល្មើស៖
  - លួចឆ្លងដែនដោយខុសច្បាប់ **៦៥**លើក ជនល្មើស **២៣០**នាក់ មាន **១០**សញ្ជាតិ
  - ស្នាក់នៅ និងធ្វើការខុសច្បាប់ **១០០**លើក ជនល្មើស **៤០៥**នាក់ មាន **២១**សញ្ជាតិ
  - ស្នាក់នៅលើសទិដ្ឋាការកំណត់ **២២៦**លើក ជនល្មើស **២២៦**នាក់ មាន **៣៩**សញ្ជាតិ។

**៣-ការឃាត់ខ្លួន និងការបណ្តេញជនបរទេសល្មើសច្បាប់៖** បានឃាត់ខ្លួនជនបរទេស និងរៀបចំតាមនីតិវិធីបណ្តេញចេញជនបរទេសល្មើសច្បាប់ ពីព្រះរាជាណាចក្រកម្ពុជា មានចំនួន **១៩៥**លើក ជនល្មើសចំនួន **៦៥៤**នាក់(ស្រី **១១០**នាក់) មាន **២៨**សញ្ជាតិ (ច្រើនជាងគេគឺជនជាតិវៀតណាម **២៣៣**នាក់, ចិន **១៩៤**នាក់, ថៃ **៩២**នាក់, ឥណ្ឌូនេស៊ី **៤៧**នាក់, តៃវ៉ាន់ **២០**នាក់, ឥណ្ឌា **១៥**នាក់, កូរ៉េខាងត្បូង **១១**នាក់, បង់ក្លាដែស **០៧**នាក់,ជប៉ុន **០៦**នាក់,នីហ្សេរីយ៉ា **០៥**នាក់ និង **១៨**សញ្ជាតិទៀត មានពី **០១** ដល់ **០៨**នាក់)។ គិតចាប់ពីបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ឆ្នាំ២០១៤ មកដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤នេះ បានបណ្តេញចេញជនបរទេសខុសច្បាប់ចំនួន **២៨.៥២៤**នាក់ មានចំនួន **១០៧**សញ្ជាតិ។

**២.៥.វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ** ៖ ស្នងការដ្ឋាននគរបាល និងកងរាជអាវុធហត្ថរាជធានី-ខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន **៧១**លើក និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើ

កិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម ដល់ម្ចាស់ជាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សាខារ៉ាអូខេ ជាប្រចាំ បានចំនួន ២៧០គោលដៅ មានចំនួនមនុស្សសរុប ១.៤៨៦នាក់(ស្រី ១.០៩៦នាក់)។

**២.៦.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ **ក្រសួងមហាផ្ទៃ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ៤៩២នាក់ ក្នុងនោះ(ស្ត្រីខ្មែរ ៤៤៣នាក់ និងស្ត្រីបរទេស ៤៩នាក់) មាន ៣០សញ្ជាតិ និងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅក្រៅប្រទេសតាមរយៈទូរស័ព្ទចំនួន ០៤នាក់(ស្រី ០៤នាក់) ប្រទេសចិន ០៤នាក់(ស្រី) ពួកគាត់សុខសប្បាយធម្មតាទេ។

**៣. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្ម**

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖ (១)-បានផ្តល់ទិដ្ឋាការដល់សហគ្រាស ដែលបានស្នើសុំប្រើប្រាស់កម្មករនិយោជិតក្មេងចំនួន ០៤សហគ្រាស, (២)-បានចុះត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងវិស័យការងារក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC) ចំពោះករណីសង្ស័យការប្រើប្រាស់ពលកម្មកុមារ ជូន យឹប អិនធើណេសិនណល(ខេមបូឌា) ឯ.ក ដែលមានទីតាំងស្ថិតនៅក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលបានរកឃើញកុមារសង្ស័យ មានស្រុកកំណើតនៅខេត្តតាកែវ។

▪ **ខេត្តសៀមរាប៖** ១-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះផ្សព្វផ្សាយតាមដានត្រួតពិនិត្យ និងទប់ស្កាត់ពលកម្ម កុមារងាយរងគ្រោះ តាមស្រុកគោលដៅ ក្នុងវិស័យឧស្សាហកម្ម (ចំការដំឡូងមី និងសិប្បកម្មផលិតឥដ្ឋ) បានចំនួន ០២លើកនៅតាមកសិឧស្សាហកម្មចំការដំឡូងមី និងចំការស្វាយចន្ទី ចំនួន ០៦កន្លែង ដែលមានកម្មករសរុប ៤៧៦នាក់ (ស្រី ២២៧នាក់) ក្នុងនោះពុំមានការប្រើប្រាស់កម្លាំងពលកម្មកុមារទេ។

▪ **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍សរុបចំនួន ១.១៣៣នាក់។

▪ **ខេត្តបន្ទាយមានជ័យ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើបច្ចុប្បន្នភាពនៅសិប្បកម្មផលិតឥដ្ឋ ស្ថិតក្នុងឃុំទឹកជោ ស្រុកព្រះនេត្រព្រះ ចំនួនពីរកន្លែង មានកម្មករនិយោជិតបម្រើការងារ ចំនួន ១១នាក់ (ស្រី ០៥នាក់) និងកុមារអាយុក្រោម១៥ឆ្នាំ រស់នៅជាមួយគ្រួសារ ០៦នាក់ (ស្រី ០៣នាក់) ក្នុងនោះពុំមានការប្រើប្រាស់កម្លាំងពលកម្មកុមារទេ។

▪ **ខេត្តប៉ៃលិន៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មនៅឡឥដ្ឋ ចំនួន ០៣កន្លែង ក្នុងនោះពុំមានការប្រើប្រាស់កម្លាំងពលកម្មកុមារទេ។

**៤. ការលើកកម្ពស់ជីវភាព និងការផ្តល់ឱ្យមានអាជីពការងារ និងវិជ្ជាជីវៈ សម្រាប់ទីផ្សារការងារ**

**៤.១. ការផ្តល់ព័ត៌មានការងារ និងបង្កើតកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ**

❖ **ថ្នាក់ជាតិ៖**

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖ បានពង្រឹង និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ៖ (១)-រៀបចំវគ្គណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរ ទៅបរទេស ចំនួន ៣៧០លើក ដែលមានពលករចំនួន ១១.០១៦នាក់ (ស្រី ៤.១០៧នាក់), (២)-ប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៩៦.៥៦៤កន្លែង និងវគ្គអប់រំបណ្តុះបណ្តាល និងអាហារូបករណ៍ចំនួន ៦២៨វគ្គ ពីគ្រប់ប្រភព, (៣)-រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីជំនាញទន់ចំនួន ១៤វគ្គ ដែលមានអ្នកចូលរួមចំនួន ៤២៥នាក់, ផ្តល់សេវាប្រឹក្សាយោបល់ អំពីអាជីពការងារ និងវិជ្ជាជីវៈដល់សិស្ស និស្សិតនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងសកលវិទ្យាល័យ ចំនួន ២.០៣៦នាក់ (ស្រី ១០៨២នាក់), (៤)-ផ្តល់កម្មវិធីតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាមធ្យមសិក្សាចំណោះទូទៅ ០១សាលា ដែលមានសិស្សសរុបចំនួន ០៦នាក់ (ស្រី គ្មាន), (៥)-រៀបចំពិព័រណ៍ការងារចល័តចំនួន ១០ដង ដែលមាន

អ្នកចូលរួមចំនួន ៩២៧នាក់(ស្រី ៥៦៤នាក់), (៦)-រៀបចំកម្មវិធីវេទិកាការងារចំនួន ២២ដង ដែលមានអ្នកចូលរួមចំនួន ៣.០៨១នាក់, (៧)-ផ្សព្វផ្សាយតាមប្រព័ន្ធ Online ចំនួន ៥.៤០០ដង, (៨)-បងក្រង និង ផលិតស្ពតផ្សព្វផ្សាយចំនួន ៨១.៤៨១ដង, (៩)-ធ្វើកម្មវិធី Roadshow និងផ្សព្វផ្សាយនៅតាមសហគមន៍ ចំនួន ៥៤១ដង ដែលមានសិស្សចំនួន ៤២.៨៧៤នាក់ (ស្រី ២១.១៣១នាក់), (១០)-គេហទំព័រការងារទីភ្នាក់ងារជាតិមុខរបរ និងការងារ មានអ្នកចូលប្រើប្រាស់ចំនួន ៨៣៩.១៤២លើក, (១១)- គេហទំព័រ Facebook អ្នកទទួលបានព័ត៌មានអំពីទីផ្សារការងារចំនួន ១២៣.៨៦៩នាក់, (១២)-កម្មវិធីស្វែងរកការងារលើទូរស័ព្ទវៃឆ្លាតមានអ្នកប្រើប្រាស់សេវាចំនួន ៣.៣៥៧នាក់,

❖ **ថ្នាក់ក្រោមជាតិ៖**

▪ **ខេត្តបន្ទាយមានជ័យ (អង្គការ IOM)** ៖ ១-បើកវគ្គតម្រង់ទិស ស្តីពីធ្វើការសម្រេចចិត្តដែលប្រកបដោយសុវត្ថិភាព ដើម្បីណែនាំដល់ពលករវិលត្រឡប់មកពីថៃ ចំនួន ៣២៨នាក់ (ស្រី ១២៧នាក់),

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៥៧ករណី(ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២៣ មានចំនួន ៤៨ករណី កើនឡើងចំនួន ០៩ករណី) ស្មើនឹង ១៥,៧៨% និងបាន៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៦៧នាក់/៥៥នាក់ (ស្រី ០៤នាក់) ។
- សង្គ្រោះជនរងគ្រោះ ចំនួន ៩៦នាក់/២០៣នាក់(ស្រី ៦៧នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ ៤៦នាក់ (ស្រី) អាយុ១៥-១៧ឆ្នាំ ០៧នាក់ និងអាយុពី១៨ឆ្នាំឡើង ៤៣នាក់(ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១៨នាក់ ប្រគល់ឱ្យអន្តោប្រវេសន៍ ២៤នាក់ និងប្រគល់ឱ្យគ្រួសារ ៥៤នាក់) ក្នុងនោះចែកជា៖

#### ១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១២ករណី/០៥ករណី(កើន ០៧ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៩នាក់ ។ សង្គ្រោះជនរងគ្រោះចំនួន ៣៨នាក់(ស្រី ០៩នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ ០៣នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ៣៤នាក់( ប្រគល់ឱ្យមន្ទីរសង្គមកិច្ចចំនួន ០២នាក់ ប្រគល់ឱ្យអន្តោប្រវេសន៍ ២៤នាក់ និងប្រគល់ឱ្យគ្រួសារ ១២នាក់។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|---|
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ២០ | ០២ | ០៨ | ០៣ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | | | | |
| -អំពើនាំឆ្លងដែន | ១១ | ០៦ | ១២ | ០៩ |
| -អំពើលក់ដូរមនុស្ស | ១៨ | ០២ | ១៤ | ០២ |
| | ១៤ | ០២ | ០៤ | ០៥ |
| *សរុប* | | *១២ករណី* | *៣៨នាក់* | *១៩នាក់* |

### ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ៤៥ករណី/៤៣ករណី(កើន ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៤៨នាក់(ស្រី ០៤នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៥៨នាក់(ស្រី ៥៨នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ៤៣នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ ១៨ឆ្នាំឡើង ០៩នាក (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១៦នាក់ និងប្រគល់ឱ្យគ្រួសារ ៤២នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ញារកម្ម | ២៧ | ០១ | ០២ | ០១ |
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២៨ | ០២ | ១៤ | ០៣ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ៤១ | ០២ | ០១ | ០២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២ | ៣៥ | ៣៥ | ៣៧ |
| -អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤៣ | ០៥ | ០៦ | ០៥ |
| *សរុប* | | *៤៥ករណី* | *៥៨នាក់* | *៤៨នាក់* |




## ២-កិច្ចការយុត្តិធម៌

### ២.១.ចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារជំនាញកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោមៈ

**១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្តៈ**

សំណុំរឿងសរុបមានចំនួន ៨៩ (ក្នុងនោះសំណុំរឿងចាស់មានចំនួន ២៧)

-ជនរងគ្រោះសរុបមានចំនួន ១០៣នាក់ (ស្រី ៤៧នាក់) ក្នុងនោះអនីតិជន ៥៨នាក់ (ស្រី ២៥នាក់) និងជនបរទេស ០១នាក់ (ស្រី)។

-ជនល្មើសសរុបមានចំនួន ១២២នាក់ (ស្រី ០៨នាក់) ក្នុងនោះអនីតិជន ២៣នាក់ (ស្រី ០០នាក់) និងជនបរទេស ០២នាក់(ស្រី ០១នាក់)។

- **សំណុំរឿងចាត់ការរួចៈ** ៨៦សំណុំរឿង មានដូចជាៈ បញ្ជូនទៅស៊ើបសួរ ៦៨សំណុំរឿង, បញ្ជូនរឿងទៅជម្រះ ១៨ សំណុំរឿង
- និងកំពុងចាត់ការ ០៣ សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោមៈ

*តារាង ដំណាក់កាលអយ្យការ ស្តីពីបទល្មើសជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ*

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនល្មើស | | | | | | | សំណុំរឿងចាត់ការរួច | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | អញ្ញត្តិជន | បញ្ជូនទៅស៊ើបសួរ | បញ្ជូនរឿងទៅជម្រះ | ទទួលដីកាបញ្ជូនខ្លួនភ្លាម | តម្កល់រឿង ទុកឥតចាត់ការ | បញ្ចូលសំណុំរឿង | ផ្ទេរសមត្ថកិច្ច | រឿងកំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | | | |
| ២៧ | ២៣ | ២១ | ៣៣ | ២៥ | ០ | ១ | ៩០ | ០៧ | ២៣ | ០ | ១ | ១ | ០ | | | | | | | |
| ៦២ | សរុប ៤៤ | | សរុម ៥៨ | | សរុប ០១ | | សរុប ៩៧ | | សរុប ២៣ | | សរុប ២ | | ០ | ៦៨ | ១៨ | ០ | ០ | ០ | ០ | ៣ |
| សរុបរួម ៨៩ | សរុបរួម ១០៣នាក់ ស្រី៤៧នាក់ | | | | | | សរុបរួម ១២២នាក់ ស្រី ០៨នាក់ | | | | | | | សរុប ៨៦ សំណុំរឿង | | | | | | ៣ សំ.រឿង |

**២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត៖**

សរុបមានចំនួន **១៩៣** សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់មានចំនួន **៧០** និងថ្មី **១២៣**)

-ជនរងគ្រោះសរុបចំនួន **១៥៤**នាក់ (ស្រី **៥២**នាក់) ក្នុងនោះអនីតិជន **៦៣**នាក់ (ស្រី **២៧**នាក់) និង ជនបរទេស **៣០**នាក់(ស្រី **០៧**នាក់)

-ជនត្រូវចោទសរុបចំនួន **១៨៨**នាក់ (ស្រី **២៣**នាក់) ក្នុងនោះអនីតិជន **១៦**នាក់ (ស្រី **០១**នាក់) និង ជនបរទេស **២១**នាក់ (ស្រី **០៧**នាក់) ។

- **សំណុំរឿងប្រភេទចំណាត់ការរួចៈ ៧៣** សំណុំរឿង មានដូចជា៖ បានបញ្ជូនរឿងទៅជម្រះចំនួន**៦៧** សំណុំរឿង, លើកលែងចោទ **០៥**សំណុំរឿង, ផ្ទេរសមត្ថកិច្ច **០១**សំណុំរឿង និង
- កំពុងចាត់ការចំនួន **១២០** សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោម៖

*តារាង ដំណាក់កាលចៅក្រមស៊ើបសួរ ស្តីពីបទល្មើសជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ*

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនត្រូវចោទ | | | | | | | | | រឿងចាត់ការរួច | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ | | អញ្ញត្តិជន | បញ្ជូនរឿងទៅជម្រះ | លើកលែងចោទ | ផ្ទេរសមត្ថកិច្ច | បញ្ចូល ២រឿង | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ចំនួនរឿង | ចំនួនស្រី | | | | | | |
| ៧០ | ៤៣ | ១៨ | ៣៦ | ២៧ | ២៣ | ០៧ | ១៣៦ | ១៥ | ១៥ | ០១ | ១៤ | ០៧ | ០ | ០ | ០ | ៦៧ | ០៥ | ០១ | ០ | ១២០ |
| ១២៣ | ៦១នាក់ | | ៦៣នាក់ | | ៣០នាក់ | | ១៥១នាក់ | | ១៦នាក់ | | ២១នាក់ | | ០ | | ០ | | | | | |
| ស.រួម ១៩៣ | សរុបរួម ១៥៤នាក់/ស្រី ៥២នាក់ | | | | | | សរុបរួម ១៨៨នាក់/ស្រី ២៣នាក់ | | | | | | | | | រឿងចាត់ការរួចចំនួនៈ៧៣<br>រឿងកំពុងចាត់ការចំនួនៈ ១២០ | | | | |

៣. ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្តៈ

សរុបមានចំនួន **១៤៥** សំណុំរឿង ក្នុងនោះ(សំណុំរឿងចាស់មានចំនួន **៦៦** និងថ្មី **៧៩**)

-ជនរងគ្រោះសរុបមានចំនួន **៣៤២**នាក់ (ស្រី **៩៥**នាក់) ក្នុងនោះអនីតិជន **៦៩**នាក់(ស្រី **៣២**នាក់) និង ជនបរទេស **០២**នាក់ (ស្រី **០០**នាក់)។

-ជនជាប់ចោទសរុបមានចំនួន **២៤៨**នាក់ (ស្រី **៥៣**នាក់) ក្នុងនោះអនីតិជន **១៤**នាក់(ស្រី **០១**នាក់)។

- **សំណុំរឿងចាត់ការរួចៈ** បានជំនុំជម្រះសរុបចំនួន **៣៦**សំណុំរឿងៈ
  - **ប្រកាសសាលក្រម** ឲ្យរួចផុតពីការចោទប្រកាន់ **១**សំណុំរឿង ចំនួនមនុស្ស **០១** នាក់ / ស្រី០នាក់
  - **ផ្តន្ទាទោស**ដាក់ពន្ធនាគារ **១៦** សំណុំរឿង ដាក់ពន្ធនាគារ ចំនួនមនុស្ស ០៨នាក់/ ស្រី ០០នាក់
  - **ព្យួរទោសធម្មតា** ៥ សំណុំរឿង ចំនួនមនុស្ស **៥**នាក់ /ស្រី ០០ នាក់
- **រឿងកំពុងចាត់ការ ១០៩** សំណុំរឿង។

*តារាង ដំណាក់កាលចៅក្រមជំនុំជម្រះ ស្តីពីបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនជាប់ចោទ | | | | | | | សំណុំរឿងចាត់ការរួច | | | | | | | | | | | | | | | | រឿងកំពុងចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | [illegible] | បញ្ជូនទៅ | [illegible] | ប្រកាសសាលក្រម | | | | | | | | | | | បណ្ដឹងឧទ្ធរណ៍ | | សរុបចាត់ | |
| | | | | | | | | | | | | | | | | រួចផុតបទចោទ | | | ផ្តន្ទាទោស | | | | ទោសព្យួរ | | | | | | | |
| | | | | | | | | | | | | | | | | សំណុំរឿង | ចំនួនមនុស្ស | | ពិន័យជាប្រាក់ | ដាក់ពន្ធនាគារ | ចំនួនមនុស្ស | | ទោសព្យួរ[illegible] | ទោសព្យួរ[illegible] | ចំនួនមនុស្ស | | បណ្ដឹង | បណ្ដឹងឧទ្ធរណ៍ | | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | | | | |
| | ២០៨ | ៦៣ | ៣៧ | ៣២ | ០២ | ០០ | ១៨២ | ៥២ | ១៣ | ០១ | ០០ | ០០ | ០០ | | | | | | | | | | | | | | | | | |
| សរុប ១៤៥ | ២៧១ | | ៦៩ | | ០២ | | ២៣៤ | | ១៤ | | ០០ | | ០ | | | | | | | | | | | | | | | | | |
| | សរុប ៣៤២នាក់ ស្រី ១០០ នាក់ | | | | | | សរុប ២៤៨ នាក់ ស្រី៥៣នាក់ | | | | | | | ៣៦ | ០ | ១ | ១ | ០ | ០ | ១៦ | ០៨ | ០ | ០ | ៥ | ៥ | ០ | ០ | ០ | ៣៦ | ១០៩ |



## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស)ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ១.១. ការទទួល និងសម្ភាសពលរដ្ឋខ្មែរបញ្ជូនត្រឡប់ តាមផ្លូវគោក និងផ្លូវអាកាស

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, អគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ៤.៨៤១នាក់(ស្រី ១.៦៧២នាក់) ក្នុងនោះកុមារ ៥៥៩នាក់(កុមារី ១៦៨នាក់) មានសកម្មភាពដូចជា៖

**១-នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ** បានទទួលចំនួន ៦៦នាក់(ស្រី ៦៤នាក់ កុមារី ០២នាក់) មកពីប្រទេសចិន ៦៥នាក់(ស្រី ៦៣នាក់ កុមារី ០២នាក់) និងប្រទេសម៉ាឡេស៊ី ០១នាក់(ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ៦២នាក់ ងាយរងគ្រោះ ០២នាក់ និងជនមានវិបល្លាសស្មារតី ០២នាក់) បានសម្ភាសន៍កំណត់អត្តសញ្ញាណបឋម ដើម្បីផ្តល់សេវាសមស្របចំនួន ៤៩នាក់(កុមារី០១នាក់) និងបានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។

**២-មណ្ឌលសំចតប៉ោយប៉ែត៖** បានទទួលពលករចំណាកស្រុកដែលបញ្ជូនត្រឡប់ពីប្រទេសថៃចំនួន២.៤៦០នាក់(ស្រី ៨១៦នាក់) កុមារ ៣១៣នាក់ (កុមារី ១៣២នាក់) បានកំណត់អត្តសញ្ញាណបឋមរកឃើញថាជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្មចំនួន ២៣នាក់(ស្រី ០៣នាក់) កុមារ ០៥នាក់(កុមារី ០៥នាក់) និងការរំលោភបំពាន កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ០១នាក់(កុមារី) ហើយជនរងគ្រោះខាងលើក៏បានបញ្ជូនទៅទទួលសេវានៅអង្គការរតនៈអ៊ីនធីនេសិនណល ១០នាក់(ស្រី ០៣នាក់) អង្គការ IJM ចំនួន ០២នាក់(ប្រុស), អង្គការដំណក់ទឹក ០៣នាក់(កុមារី), អង្គការគ្រួសារថ្មី ០៤នាក់(កុមារី ០២នាក់), អង្គការក្តីស្រឡាញ់គ្មានព្រំដែន ០៣នាក់(កុមារី ០១នាក់) និងទៅសហគមន៍ ០២នាក់(ប្រុស)។

**៣-មណ្ឌលកំរៀង៖** បានទទួលពលករចំណាកស្រុក ដែលបញ្ជូនត្រឡប់ពីប្រទេសថៃ ចំនួន ២៦៨នាក់(ស្រី ៩៥នាក់) ក្នុងនោះកុមារ ៦១នាក់(កុមារី ២៨នាក់) ស្ត្រីមានកូនតូច ០៩នាក់ និងស្ត្រីមានផ្ទៃពោះ ០១នាក់ បានកំណត់អត្តសញ្ញាណបឋម រកឃើញថាសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ៣០នាក់(ស្រី ១០នាក់) ហើយពលករខាងលើនេះក៏បានបញ្ជូន ទៅសហគមន៍វិញ។

**៤-អគ្គស្នងការដ្ឋាននគរបាលជាតិ** មានស្នងការដ្ឋាននគរបាលខេត្ត ចំនួន ០៣ បានទទួល និងសម្ភាសពលករ និងពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ក្នុងនោះមាន(ច្រកចាំយាម ច្រកធម្មជាតិ) និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម បានចំនួន ១៤៣លើក សរុបមនុស្សចំនួន ២.០៤៧នាក់(ស្រី ៦៩៧នាក់ កុមារ ១៨៣នាក់(កុមារី ៦១នាក់ ក្នុងនោះមាន៖

- **ខេត្តកោះកុង៖** បានចំនួន ២៨លើក មនុស្សចំនួន ៧១នាក់ ស្រី ១៦នាក់។
- **ខេត្តបន្ទាយមានជ័យ** ចំនួន ១០៩លើក មនុស្ស ១.៩១៧នាក់ (ស្រី ៦៤២នាក់) កុមារ ១៤៩នាក់(កុមារី ៦១នាក់)។
- **ខេត្តស្វាយរៀង៖** បានចំនួន ០៦លើក មនុស្សចំនួន ៥៩នាក់(ស្រី៣៩នាក់ កុមារ ៣៤នាក់)។

**ដោយឡែក៖** ១-បានទទួលជនរងគ្រោះ និងងាយរងគ្រោះពីសមត្ថកិច្ចនៅក្នុងស្រុកចំនួន ៩០នាក់(ស្រី០៦នាក់) ជាជនបរទេស មាន០៦សញ្ជាតិរួមមាន៖ បង់ក្លាដេស៥១នាក់ ចិន១៧នាក់ ឥណ្ឌា០៥នាក់ វៀតណាម១៤នាក់(ស្រី ០៥នាក់) ឥណ្ឌូនេស៊ី០១នាក់ ស្រីលង្កា០១នាក់ និងជនជាតិខ្មែរ ០១នាក់(ស្រី) (ជាករណីជួញដូរកម្លាំងពលកម្ម)។

២-បានទទួលជនរងគ្រោះ និងងាយរងគ្រោះពីមន្ទីរ ស.អ.យ រាជធានី-ខេត្ត និងអង្គការដៃគូ ចំនួន២១នាក់ (ស្រី ១៤នាក់) ដូចជាករណីធ្វើអាជីវកម្មផ្លូវភេទ ១១នាក់(ស្ត្រី) និងជាករណីជួញដូរកម្លាំងពលកម្ម ១០នាក់(ស្ត្រី ០៣នាក់)។

## ២. កិច្ចការពារជនរងគ្រោះ ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា នៅមណ្ឌលរបស់អង្គការដៃគូ សរុប ១៥៦នាក់( ស្រី ៧០នាក់ កុមារី ០២នាក់) ក្នុងនោះករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ ៦៣នាក់(ស្ត្រី ៦១នាក់ កុមារី ០២នាក់) កេងប្រវ័ញ្ចកម្លាំងពលកម្ម ៨៩នាក់(ស្ត្រី ០៥នាក់) និងជនវិបល្លាសស្មារតី ០២នាក់ និងងាយរងគ្រោះ ០២នាក់ រួមក៏បានបញ្ជូនទៅអង្គការការីតាសកម្ពុជា, សមាគម ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(អាដហុក), អង្គការរតនៈអ៊ិនធើណេណល, អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិIJM, អង្គការមូលនិធិហាការអន្តរជាតិ, អង្គការសម្ព័ន្ធចាប់ដៃ, អង្គការមូលនិធិ A21, អង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ CWCC និងមជ្ឈមណ្ឌលថែទាំនិងស្តារនីតិសម្បទាជនវិបល្លាសស្មារតី ។

## ៣.ការធ្វើសមាហរណកម្ម ពលរដ្ឋខ្មែរដែលជាជនរងគ្រោះ និងងាយរងគ្រោះ

### ៣.១. ការធ្វើសមាហរណកម្ម

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប ២៦នាក់(ស្រី ២៥នាក់) ជាករណីរំលោភបំពានផ្លូវភេទ ២៥នាក់(ស្រី) និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ០១នាក់ ដោយមានការចូលរួមសហការគាំទ្រពីអង្គការដៃគូ។

➢ និងបានធ្វើមាតុភូមិនិវត្តន៍ ទៅប្រទេសដើមវិញ ចំនួន ៤៨នាក់(ស្រី ចំនួន ១៧នាក់) ជាករណីជួញដូរកម្លាំងពលកម្ម ជនរងគ្រោះជនជាតិ ហ្វីលីពីន ២៧នាក់(ស្រី ១២នាក់), ថៃចំនួន ០៤នាក់ (ស្រី ០១នាក់), វៀតណាម ០៨នាក់(ស្រី ០៣នាក់), ឥណ្ឌា ០៨នាក់ (ស្ត្រី ០១នាក់) និងជនជាតិឥណ្ឌូនេស៊ី ០១នាក់។

### ៣.២. ការបិទករណី

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយអង្គការដៃគូ បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ២៧នាក់(ស្រី ២១នាក់) មានករណី (ធ្វើអាជីវកម្មផ្លូវភេទ ១៦នាក់(ស្រី) កេងប្រវ័ញ្ចកម្លាំងពលកម្ម ១១នាក់(ស្រី ០៥នាក់) និងងាយរងគ្រោះ ៤២នាក់។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ១. ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស

### ១.១ ការងារបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត(គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយ អង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលចំនួន ៦១វគ្គ មានសិក្ខាកាមចូលរួមចំនួន ២.០០៩នាក់ ក្នុងនោះមានស្ត្រី ៩៥៥នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោម៖

| |
|---|
| ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំបើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្តកសាងសមត្ថភាពដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ស្តីពី៖ ១-ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកខុសច្បាប់ និងកិច្ចការពារកុមារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ។ ២-នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ៣-ស្តីពី |

| ការគ្រប់គ្រងករណីនៃមាតុកូមិនិវត្តន៍ និងធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ៤-ការទប់ស្កាត់ ការការពារ និងការឆ្លើយតប ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ | | | |
|---|---|---|---|
| **សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល** | **ចំនួនវគ្គ** | **សិក្ខាកាមសរុប** | **សិក្ខាកាមជានារី** |
| **ថ្នាក់ជាតិ** | | | |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសហការជាមួយអង្គការ ( IOM) | ០៧ | ២៥៧ | ១៥០ |
| អគ្គស្នងការដ្ឋាន នគរបាលជាតិ សហការជាមួយអង្គការមេត្រីអន្តរជាតិ(AIM SWAT ) | ០១ | ២០ | ០៤ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយអង្គការដៃគូ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) អង្គការវីនរ៉ក់អន្តរជាតិ( WINROOK ) និងអង្គការមេត្រីអន្តរជាតិ( AIM SWAT), (IOM) | ០៨ | ២៤០ | ៩៤ |
| កាកបាទក្រហមកម្ពុជា | ០២ | ២៥ | ០៩ |
| អង្គការជំនួយផ្លូវច្បាប់ស្រ្តីនិងកុមារ( ខេត្តស្វាយរៀង ) | ០១ | ៤៨ | ២៦ |
| អង្គការ IOM ( ខេត្តឧត្តរមានជ័យ, ខេត្តស្ទឹងត្រែង ) | ០២ | ៧០ | ៤៨ |
| អង្គការការីតាស់ស្វីស( ខេត្តបាត់ដំបង ) | ០១ | ១៤៧ | ៧៧ |
| **សរុប** | **២២វគ្គ** | **៨០៧នាក់** | **៤០៨នាក់** |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបាត់ដំបង | ០១ | ៥១ | ១៣ |
| ខេត្តព្រះវិហារ | ០១ | ១០០ | ១១ |
| ខេត្តបន្ទាយមានជ័យ | ០៤ | ៣៣១ | ១៨៦ |
| ខេត្តកំពង់ធំ | ០១ | ៤០ | ២៣ |
| ខេត្តស្វាយរៀង | ២៩ | ៥៥៦ | ២៦៨ |
| ខេត្តស្ទឹងត្រែង | ០១ | ៤៤ | ០៤ |
| ខេត្តរតនគិរី | ០១ | ៥២ | ៤២ |
| ខេត្តព្រៃវែង | ០១ | ២៨ | ០០ |
| **សរុប** | **៣៩វគ្គ** | **១.២០២នាក់** | **៥៤៧នាក់** |
| **សរុបរួម** | **៦១វគ្គ** | **២.០០៩នាក់** | **៩៥៥នាក់** |

## ២. សិក្ខាសាលា

### ២.១. សិក្ខាសាលាក្នុងប្រទេស

ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ ( គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំសិក្ខាសាលាដើម្បីពង្រឹងសមត្ថភាពដល់មន្រ្តីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ បានចំនួន **៣០៦**វគ្គ មានសិក្ខាកាមចូលរួមចំនួន **១៥.៨២៦**នាក់ ក្នុងនោះមានស្ត្រី **៨.៤៤៨**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំសិក្ខាសាលា ដើម្បីពង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ស្តីពី៖ ១-ពិនិត្យ សម្រេចលើសេចក្តីព្រាងចុងក្រោយ ផែនការយុទ្ធសាស្រ្តជាតិ ៥ឆ្នាំ (២០២៤-២០២៨) ២-បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ ៣-ស្តីពី ការបង្ហាញលទ្ធផលនិងអនុសាសន៍ពីការពិគ្រោះយោបល់ជាមុនសម្រាប់ការពិនិត្យគោលការណ៍ណែនាំ ដើម្បីការកំណត់ អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស | | | |
|---|---|---|---|
| **សកម្មភាពរៀបចំសិក្ខាសាលា** | **ចំនួនលើក** | **ចំនួនអ្នកចូលរួម** | **ចំនួនស្រី** |

| ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | | | |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ សហការជាមួយអន្តរក្រសួង និងអង្គការដៃគូ | ០១ | ៣៣២ | ១៤១ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣០៤ | ១៥.៤៣៩ | ៨.២៨៨ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០១ | ៥៥ | ១៩ |
| សរុប | ៣០៦លើក | ១៥.៨២៦នាក់ | ៨.៤៤៨នាក់ |

## ២. កិច្ចប្រជុំ សន្និសីទ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

#### ១.១. កិច្ចប្រជុំក្នុងប្រទេស

សមាជិកនៃគ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំកិច្ចប្រជុំដើម្បីពង្រឹងសមត្ថភាព ដល់មន្ត្រីពាក់ព័ន្ធ សរុបចំនួន **១៣៦**លើក មានអ្នកចូលរួមចំនួន **២.៨០៨**នាក់ ក្នុងនោះមានស្ត្រី **១.២២៧**នាក់ដូចមានក្នុងតារាងខាងក្រោម៖

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំកិច្ចប្រជុំពិភាក្សា ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ដើម្បីពង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពី៖ **១**-ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ។ **២**-រកធាតុចូលត្រៀមរបាយការណ៍សន្និបាតប្រចាំឆ្នាំ របស់ក្រសួងមហាផ្ទៃ, **៣**-បញ្ហាសុខភាពសម្រាប់ជនទេសន្តរប្រវេសន៍ នៃបណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក, **៤**-គោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស, **៥**-ការផ្តល់ព័ត៌មានដែលជាធាតុចូលដល់របាយការណ៍នៃការជួញដូរមនុស្សប្រចាំឆ្នាំ របស់ក្រសួងការបរទេស នៃសហរដ្ឋអាម៉េរិក, **៦**-ស្តីពីទេសន្តរប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា។

| សកម្មភាពរៀបចំកិច្ចប្រជុំរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ២៩ | ៥៦៤ | ២៧៧ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០១ | ៤៣ | ១៩ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០៦ | ១១៣ | ៣៦ |
| សរុប | ៣៦លើក | ៧២០នាក់ | ៣៣២នាក់ |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបន្ទាយមានជ័យ សហការជាមួយ អង្គការ IOM | ០១ | ៨៥ | ៣៥ |
| ខេត្តសៀមរាប | ៣១ | ៩៥២ | ៣៧២ |
| ខេត្តក្រចេះ | ០១ | ៤៧ | ២៤ |
| ខេត្តកំពង់ចាម | ១២ | ៨៩ | ៥៧ |
| ខេត្តស្វាយរៀង | ០១ | ៥៧ | ២៥ |
| ខេត្តកណ្តាល | ២៣ | ៦៣១ | ២៦៩ |
| ខេត្តកំពត | ២៨ | ១៦០ | ៨៥ |
| ខេត្តរតនគិរី | ០១ | ១៣ | ០៧ |
| ខេត្តកំពង់ឆ្នាំង | ០២ | ៥៤ | ២១ |
| សរុប | ១០០លើក | ២.០៨៨នាក់ | ៨៩៥នាក់ |
| **សរុបរួម** | **១៣៦លើក** | **២.៨០៨នាក់** | **១.២២៧នាក់** |

## ២. ទស្សនកិច្ច

❖ ថ្នាក់ជាតិ

▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំមន្ត្រីជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ធ្វើទស្សនកិច្ចនៅមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ដំណើរទស្សនកិច្ចក៏បានធ្វើការសំណេះសំណាលជាមួយក្រុមការងារ នៃមណ្ឌលទទួលពលករកំរៀង ព្រមទាំងមន្ត្រីសាលាស្រុក នគរបាលនៃអធិការដ្ឋាននគរបាលស្រុក អាវុធហត្ថស្រុក កម្លាំងការពារព្រំដែនគោក និងមន្ត្រីនៃការិយាល័យការងារស្រុកកំរៀង។

## ៣. ជំនួបពិភាក្សាការងារ

❖ ថ្នាក់ជាតិ

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជួបពិភាក្សាការងារជាមួយ៖ **១**-គណៈប្រតិភូអង្គការ សហប្រជាជាតិ មានឯកឧត្តម Joseph Scheuer តំណាង អង្គការសហប្រជាជាតិប្រចាំកម្ពុជា លោកស្រី Roueida El Hage តំណាងឧត្តមស្នងការសិទ្ធិមនុស្ស OHCHR នៅកម្ពុជា លោកស្រី Alissa Chaker តំណាងអង្គការ UNDP ប្រចាំកម្ពុជា លោកស្រី Kristin Parco ប្រធានបេសកកម្មអង្គការ IOM កម្ពុជា ស្តីពីការពង្រឹងកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **២**-តំណាងអង្គការ អាស៊ានអាក់ ក្នុងគោលបំណងធ្វើបទបង្ហាញ ស្តីពីផែនការសកម្មភាពការងាររបស់អង្គការអាស៊ានអាក់ ក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **៣**-តំណាងពីអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ក្នុងការរៀបចំសេចក្តីព្រាងផែនការជាតិសម្រាប់អនុវត្ត កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ មានអ្នកចូលរួមចំនួន**១៤**រូប ។ **៤**-តំណាងអង្គការ IJM ស្តីពីការរៀបចំផែនការបណ្តុះបណ្តាលស្តីពីបែបបទ និងនីតិវិធី នៃកាកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របសម្រាប់ខេត្តកោះកុង បាត់ដំបង និងបន្ទាយមានជ័យ។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានទទួលជួបពិភាក្សាការងារជាមួយ៖ **ក**-អង្គការ ILO៖ **១**-ដើម្បីផ្តល់យោបល់លើឯកសារគម្រោង ស្តីពីការងារសមរម្យប្រចាំប្រទេសកម្ពុជា ឆ្នាំ២០២៤-២០២៨(DWCP) ចំនួន ០៣លើក, **២**-ពិនិត្យផែនទីបង្ហាញផ្លូវស្តីពីកាតាលីករសកលសម្រាប់មុខរបរ និងការងារ និងកិច្ចគាំពារសង្គម ជាមួយអ្នកជំនាញអង្គការអន្តរជាតិខាងការងារ (ILO) ។ **ខ**-តំណាងអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ប្រចាំកម្ពុជា។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖** លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ និងលោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានជួបពិភាក្សា និងបានផ្តល់កិច្ចសម្ភាសន៍ដល់តំណាង Jica ក្នុងគោលបំណងកែសម្រួលសៀវភៅគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

❖ ថ្នាក់ក្រោមជាតិ

▪ **ខេត្តកំពង់ឆ្នាំង៖** លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **០២**លើក។

▪ **ខេត្តឧត្តរមានជ័យ៖** ក្រុមការងារទេសន្តរប្រវេសន៍ការងារនៃមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវខេត្តកំពង់ចាម បានទទួលជួបពិភាក្សាការងារជាមួយអ្នកវាយតម្លៃមកពីប្រទេសកាណាដាលើការអនុវត្តគម្រោង ចំណាកស្រុកប្រកបដោយសុវត្ថិភាពរបស់អង្គការអន្តរជាតិខាងការងារ។

▪ **ខេត្តបន្ទាយមានជ័យ៖ ១**-ក្រុមការងារជំនាញ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយតំណាងអង្គការជីវិតថ្លៃថ្នូរ លើការអនុវត្តគម្រោងបង្ការការជួញដូរមនុស្ស តាមរយៈការលើកកម្ពស់ ជីវភាពរស់នៅរបស់ប្រជាជនដែលងាយរងគ្រោះ និងជនចំណាកស្រុកត្រឡប់មកវិញ នៅស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ មានអ្នកចូលរួម **១១**នាក់ ស្រី**០៤**នាក់។

២-មន្ទីរ ស.អ.យ ខេត្ត បានជួបពិភាក្សាជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ IOM ស្តីពីការប្រមូលព័ត៌មានលើកុមារ រងគ្រោះអំពើជួញដូរមនុស្ស។ និងធ្វើបច្ចុប្បន្នភាពលើគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់ សេវាសមស្រប។

▪ **ខេត្តសៀមរាប៖** ១-អនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយអង្គការសម្ព័ន្ធចាប់ដៃ ស្តីពីការពង្រឹងកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **២**-ក្រុមការងារជំនាញ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយតំណាងអង្គការជីវិតថ្លៃថ្នូរ លើការអនុវត្តគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តសៀមរាប មានអ្នកចូលរួម **០៦**នាក់ ស្រី **០២**នាក់។ **៣**-ក្រុមការងារជំនួយការលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយតំណាង អង្គការមូលនិធិអេ២១ ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងមត្ថភាពទៅដល់មន្ត្រីនគរបាលយុត្តិធម៌ និងក្រុមការងារ នៅថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់។ **៤**-មន្ទីរអប់រំខេត្ត បានជួបពិភាក្សាជាមួយអង្គការមូលនិធិអេ២១ លើការផ្សព្វផ្សាយអំពីការស្វែងយល់អំពីការកេងប្រវ័ញ្ចផ្លូវភេទ លើយុវជនតាមប្រព័ន្ធអនឡាញ និងការចាញ់បោកគេទៅធ្វើការនៅក្រៅប្រទេស តាមរយៈការចាក់ខ្សែភាពយន្ត នៅតាមសង្គ្រានវិទ្យាល័យ ។

▪ **ខេត្តកោះកុង៖** ក្រុមការងារជំនាញ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយអង្គការជីវិតថ្លៃថ្នូរ និងអង្គការវីនរ៉ក់អន្តរជាតិ ស្តីពីការបន្តការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងខេត្តកោះកុង។

▪ **ខេត្តកំពង់ឆ្នាំង៖** លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាជាមួយអង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ ដើម្បីសហការអនុវត្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅខេត្តកំពង់ឆ្នាំង។

▪ **ខេត្តកំពង់ចាម៖** ១-ក្រុមការងារទេសន្តរប្រវេសន៍ការងារ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលជួបពិភាក្សាការងារជាមួយ អ្នកវាយតម្លៃមកពីប្រទេសកាណាដា លើការអនុវត្តគម្រោងចំណាកស្រុកប្រកបដោយសុវត្ថិភាព របស់អង្គការអន្តរជាតិខាងការងារ(ILO) ។ **២**-អនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយអង្គការសម្ព័ន្ធចាប់ដៃ ០១លើក ស្តីពីការពង្រឹងកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**គ. ការងារសម្របសម្រួល**

គ.ជ.ប.ជ/គ.រ.ប.ជ/គ.ខ.ប.ជ និងអង្គការដៃគូ បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗទៀត ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្អែកលើផែនការជាតិយុទ្ធសាស្ត្រជាតិទាំងបួន (ការបង្ការ ទប់ស្កាត់ ការការពារ និងជួយជនរងគ្រោះ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងអំពើជួញដូរមនុស្ស) សរុបចំនួន **២១៣**លើក មានអ្នកចូលរួមសរុប **២.០៥២**នាក់ (ស្រី **១.០៥៣**នាក់) ដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាពចូលរួមរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ៥៨ | ៣៤៨ | ១៤៤ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៣ | ៦៦ | ២៨ |
| ក្រសួងអប់រំ យុវជន និងកីឡា | ១១ | ៤៨ | ២៥ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៣៩ | ២៤០ | ១៩៩ |
| អង្គការមូលនិធិអេ ២១ | ១៨ | ២៥ | ១៩ |
| **សរុប** | **១៣៨លើក** | **៧១៧នាក់** | **៤០៥នាក់** |
| **ថ្នាក់ក្រោមជាតិ** | | | |
| រាជធានីភ្នំពេញ | ០៥ | ១៩ | ០៩ |
| ខេត្តបន្ទាយមានជ័យ | ១៨ | ៧២៨ | ៤១៦ |

| | | | |
|---|---|---|---|
| ខេត្តព្រះវិហារ | ០២ | ១១ | ០៥ |
| ខេត្តបាត់ដំបង | ០៣ | ៥៨ | ៣៩ |
| ខេត្តពោធិ៍សាត់ | ០២ | ២៩ | ១៣ |
| ខេត្តសៀមរាប | ០២ | ១៧ | ០៥ |
| ខេត្តឧត្តរមានជ័យ | ០២ | ០៨ | ០៣ |
| ខេត្តប៉ៃលិន | ០២ | ០៧ | ០៣ |
| ខេត្តកោះកុង | ០៣ | ១៨ | ០៨ |
| ខេត្តក្រចេះ | ០២ | ១០ | ០៤ |
| ខេត្តស្ទឹងត្រែង | ០១ | ០៤ | ០២ |
| ខេត្តរតនគិរី | ០៣ | ៩០ | ២៧ |
| ខេត្តកំពង់ចាម | ០២ | ០៩ | ០៤ |
| ខេត្តត្បូងឃ្មុំ | ០៣ | ១៩ | ០៨ |
| ខេត្តមណ្ឌលគិរី | ០២ | ០៨ | ០៣ |
| ខេត្តស្វាយរៀង | ០៤ | ២១៦ | ៦១ |
| ខេត្តកណ្ដាល | ០២ | ០៩ | ០៣ |
| ខេត្តព្រៃវែង | ០២ | ១៣ | ០៦ |
| ខេត្តព្រះសីហនុ | ០២ | ០៩ | ០៣ |
| ខេត្តកំពត | ០២ | ០៨ | ០៤ |
| ខេត្តកែប | ០២ | ០៧ | ០៣ |
| ខេត្តតាកែវ | ០២ | ០៧ | ០៣ |
| ខេត្តកំពង់ឆ្នាំង | ០២ | ០៨ | ០៥ |
| ខេត្តកំពង់ស្ពឺ | ០២ | ១០ | ០៥ |
| ខេត្តកំពង់ធំ | ០៣ | ១៣ | ០៦ |
| **សរុប** | **៧៥នាក់** | **១.៣៣៥នាក់** | **៦៤៨នាក់** |
| **សរុបរួម** | **២១៣នាក់** | **២.០៥២នាក់** | **១.០៥៣នាក់** |

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក. ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាឋាមពលជំរុញចិត្ត ឲ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឲ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត។
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខថ្នាក់ដឹកនាំទាំងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ។

- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត ។
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ តាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិល អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប សម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជាៈ

- ការរៀបចំក្រុមមន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅតាមក្រសួងស្ថាប័ន មន្ទីរ អង្គភាពមួយចំនួន មានការផ្លាស់ប្តូរញឹកញាប់ និងអង្គភាពខ្លះមិនទាន់មានអ្នកទទួលខុសត្រូវច្បាស់លាស់ ដែលចាំបាច់ត្រូវពង្រឹងបន្ថែមទៀត ទាំងរចនាសម្ព័ន្ធ ទាំងសមត្ថភាពក្នុងការអនុវត្តភារកិច្ច ។
- នៅមិនទាន់យល់ស្របគ្នាក្នុងការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ការអប់រំផ្សព្វផ្សាយតាមវេទិកាសាធារណៈ... ដែលធ្វើឲ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា ។
- ជនល្មើសនៅតែបន្តរកកលល្បិចជ្រៀតចូលមកធ្វើសកម្មភាពខុសច្បាប់ និងអូសទាញទាំងពលរដ្ឋខ្មែរនិងជនបរទេស ឲ្យធ្លាក់ចូលទៅក្នុងភាពរងគ្រោះជាបន្តបន្ទាប់ ។
- ប្រជាពលរដ្ឋមួយចំនួន នៅមិនទាន់យល់ និងមិនទាន់មានភាពរឹងមាំក្នុងការការពារខ្លួនពីកលល្បិចជនល្មើស និងមិនទាន់មានកិច្ចសហការគ្នាល្អ ក្នុងការបង្ការទប់ស្កាត់ ។

## គ. សន្និដ្ឋាន និងសំណូមពរ

លទ្ធផលការងារ ឆ្នាំ២០២៣ បានបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគួរឲ្យកោតសរសើរ ។ ទន្ទឹមនឹងនោះ បទល្មើស ទាំងនៅក្នុងប្រទេស និងលើប្រជាជនកម្ពុជា នៅក្រៅប្រទេស នៅមិនទាន់ស្ងប់ស្ងាត់នៅឡើយទេ និងបានធ្វើឲ្យមានអ្នករងគ្រោះជាបន្តបន្ទាប់ ។ ទន្ទឹមនឹងនោះ ឆ្លងតាមការកំណត់អត្តសញ្ញាណជនរងគ្រោះ ភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែមានលាយឡំដោយបទល្មើសផ្សេងទៀត ជាអាទិ៍ អំពើឆបោក ទំនាស់ការងារ ការងារខុសច្បាប់ ឬអន្តោប្រវេសន៍ខុសច្បាប់ ឬការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម ។

ហេតុនេះ ការពង្រឹងស្ថាប័ន សមត្ថភាពមន្ត្រីអនុវត្ត និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធ នៅតែមានភាពចាំបាច់ មិនអាចខ្វះបាន ។

ជាសំណូមពរ គឺៈ

- ស្នើក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនីមួយៗ គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវដើម្បីចូលរួមក្នុងការងារប្រឆាំងការជួញដូរមនុស្សឲ្យបានច្បាស់លាស់ ងាយស្រួលដល់ការអនុវត្តភារកិច្ច។
- រៀបចំមន្ត្រីក្នុងរចនាសម្ព័ន្ធ ឲ្យទទួលបានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពតាមវិស័យពាក់ព័ន្ធ ដើម្បីយល់ច្បាស់អំពីអំពើជួញដូរមនុស្ស នីតិវិធី និងច្បាប់ពាក់ព័ន្ធ តួនាទីភារកិច្ច និងរបៀបរបបការងារដែលឆ្លើយតបទៅនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ចាត់តាំងឲ្យមានមន្ត្រីទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍ ប្រចាំអង្គភាព។

- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន ឲ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការប្រឹងប្រែងក្នុងយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅអនុវត្តត្រីមាសទី២ ឆ្នាំ២០២៤

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

### ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

១. បន្តរៀបចំ និងជំរុញអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលចាំបាច់សម្រាប់បម្រើដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

២.ធ្វើបច្ចុប្បន្នភាពសៀវភៅ គោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

៣. ពិនិត្យ ពិភាក្សាឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអំពើពពោះជំនួស ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍ប្រែប្រួលនៃបទល្មើសជួញដូរទារក ។

៤.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ។

៥.តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តអនុស្សរណៈ និងកិច្ចព្រមព្រៀង ស្តង់ដានីតិវិធីប្រតិបត្តិ ទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធដែលបានចុះហត្ថលេខារួចហើយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល។

៦.ជំរុញការពិភាក្សាជាមួយភាគីថៃ ដើម្បីបញ្ចប់ និងអនុម័តលើផែនសកម្មភាពនៃស្តង់ដារនៃនីតិវិធីប្រតិបត្តិ(SOP) ស្តីពីកិច្ចសហការក្នុងការអនុវត្តច្បាប់ ដើម្បីប្រឆាំងការជួញដូរមនុស្ស ។

៧.ពង្រឹងការតាមដានត្រួតពិនិត្យ ដើម្បីវាយតម្លៃសភាពការណ៍ប្រែប្រួលនៃបទល្មើស និងប្រសិទ្ធភាពការងារ ដែលបានអនុវត្តតាមវិស័យ ដើម្បីមានវិធានការឆ្លើយតប ។

៨.ប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធី សម្រាប់ការពារសិទ្ធិ សុវត្ថិភាព ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទសមុទ្រ។

៩.ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការ ការពារ និងបង្ការទប់ស្កាត់ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក។

១០.បន្តចុះហត្ថលេខាអនុស្សរណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងគណៈកម្មាធិការជាតិ ក្រសួង ស្ថាប័ន ឬ ជាមួយដៃគូពាក់ព័ន្ធ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

១១.បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តវិធានការច្បាប់ វិធានការបង្ការទប់ស្កាត់ វិធានការសង្គ្រោះ និងការពារជនរងគ្រោះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ខ. ការងារបង្ការ ទប់ស្កាត់

១. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បន្តសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ រៀបចំនីតិវិធី និងសកម្មភាពអប់រំផ្សព្វផ្សាយដើម្បីបង្ការទប់ស្កាត់ភាពរងគ្រោះដោយការប្រើប្រាស់ទិន្នន័យឌីជីថលដែលមិនមានសុវត្ថិភាព និងបន្តសហការជាមួយអង្គការ APLE និងអង្គការដៃគូដទៃទៀត បន្តរៀបចំយុទ្ធនាការ «គាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពនៃការប្រើប្រាស់អ៊ីនធឺណិតនិងលើកកម្ពស់សីលធម៌ដើម្បីសុវត្ថិភាពសង្គម» និង រៀបចំសិក្ខាសាលាប្រកបេញចូលតែមួយ ស្តីពី «សេវាកម្មកុមារ»។

២. ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ បន្តបើកវគ្គបណ្តុះបណ្តាលសៀវភៅសិក្សាអប់រំស្តីពី «ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន» ដល់គ្រូឧទ្ទេសក៏ថ្នាក់ជាតិ គ្រូឧទ្ទេសក៏

គរុកោសល្យភូមិភាគ និងគ្រូបង្គោល តាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នៅទូទាំងប្រទេស និងតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតខាងលើ។

៣.ក្រសួងទេសចរណ៍ បន្តការរៀបចំសិក្ខាសាលា ស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេចរណ៍ដល់ម្ចាស់មូលដ្ឋាន អាជីវកម្មសេវាកម្មទេសចរណ៍តាមបណ្តារាជធានី-ខេត្ត និងធ្វើអធិការកិច្ចគោលដៅសង្ស័យក្នុងសេវាកម្មកំសាន្ត សប្បាយ ។

៤. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា( TRC) ធ្វើការផ្សព្វផ្សាយសារអប់រំ ដល់ប្រជាពលរដ្ឋ តាមរយៈទូរស័ព្ទចល័ត នៅថ្ងៃទិវាជាតិពាក់ព័ន្ធ។

៥.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ( NEA) រដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញ និងពង្រីកការផ្សព្វផ្សាយ អំពីឱកាសការងារ មុខរបរ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងៗ ឱ្យកាន់តែទូលំទូលាយនៅតាមសហគមន៍ ជាពិសេស ពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់។

៦.ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តពង្រឹងការគ្រប់គ្រង ទីភ្នាក់ងារជ្រើសរើសឯកជន ជំរុញការអនុវត្តក្រមសីលធម៌ និងធ្វើអធិការកិច្ចជាប្រចាំ ដើម្បីធានាការអនុវត្តគោលនយោបាយ ច្បាប់ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារ ក្នុងការការពារសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ពលករក្នុងការធ្វើទេសន្តរប្រវេសន៍ការងារដោយស្របច្បាប់។

៧.បន្តរៀបចំយុទ្ធនាការនៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប និងយុទ្ធនាការសំខាន់ៗផ្សេងៗទៀត ។

៨.បន្តចូលរួមយ៉ាងសកម្មក្នុងការបញ្ជ្រាបការយល់ដឹងអំពីបទល្មើសជួញដូរមនុស្ស ការបង្ការទប់ស្កាត់ កលល្បិចជនល្មើស ផលប៉ះពាល់ វិធានការច្បាប់ ទៅក្នុងវេទិកាគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

៩.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេសអធិការកិច្ចដោយមិនជូនដំណឹងជាមុន លើគោលដៅសង្ស័យ នៅតាមរោងចក្រ សហគ្រាស សហគ្រាសឡឥដ្ឋ កសិដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ កន្លែងសេវាកម្សាន្តជាដើម និងមានវិធានការក្នុងប្រភេទការងារដែលមានភាពរងគ្រោះខ្ពស់ ដូចជានៅតាមទីភ្នាក់ងារជ្រើសរើសពលករឯកជន ។

១០.រៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន និងត្រៀមចូលរួមកិច្ចប្រជុំអន្តរជាតិនានា ។

១១.ជំរុញប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ ជាពិសេស ពលករដែលមិនមានឯកសារស្របច្បាប់ នៅក្នុងរដ្ឋ នៃទេសន្តរប្រវេសន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ និងវិធានការសម្រាប់ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ និងការផ្តល់សេវាផ្លូវច្បាប់ឱ្យបានសមស្រប ។

## គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ

១.បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

២.បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោស បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុង និងក្រៅប្រទេស ជាពិសេសបទល្មើសថ្មី ដែលបង្កដោយជនបរទេស។

៣.បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស។

៤.បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការងារអនុវត្តច្បាប់ និងយុត្តិធម៌ ព្រហ្មទណ្ឌក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន។

៥.ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

៦.បន្តពិភាក្សាទ្វេភាគី ជាមួយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សប្រទេសថៃ ដើម្បីពិនិត្យបញ្ចប់ផែនការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពីកិច្ចសហការក្នុងការអនុវត្តច្បាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស ។

**ឃ. ការងារការពារជនរងគ្រោះ**

១.បន្តពង្រឹងយន្តការសម្រាប់ការទទួលពលករ ការគ្រប់គ្រងនៅតាមព្រំដែន និងបន្តដំណើរការទទួល និងប្រមូលទិន្នន័យពលករវិលត្រឡប់ ឬបញ្ជូនត្រឡប់ កំណត់អត្តសញ្ញាណបឋមរកភាពរងគ្រោះ នៅមណ្ឌលសំចត ប៉ោយប៉ែត និងមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង ដោយមានកិច្ចសហការពីបណ្ដាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការផ្ដល់សេវា។

២.រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្ដីពីកិច្ចការពារកុមារ ក្នុងទេសន្តប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន។

៣.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តរៀបចំវគ្គបណ្ដុះបណ្ដាលៈ

គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

គោលការណ៍ណែនាំ ស្ដីពី «បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប» ដល់មន្ត្រីជួរមុខ។

៤.ធ្វើបច្ចុប្បន្នភាពលើនីតិវិធីប្រតិបត្តិបទដ្ឋាន(SOPs) ស្ដីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៥.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បន្តកិច្ចសហប្រតិបត្តិការជាមួយៈ

ក្រសួងសុខាភិបាល ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទទួលបានសេវាពិនិត្យសុខភាព និងការព្យាបាលសង្គ្រោះបន្ទាន់ដោយឥតគិតថ្លៃ នៅតាមមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។

ស្ថានទូត និងកុងស៊ុល នៅក្រៅប្រទេស(តាមរយៈក្រសួងការបរទេស) ដើម្បីជួយដល់ជនរងគ្រោះ និង សម្រួលដល់ដំណើរការមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាឱ្យបានឆាប់រហ័ស និងមានសុវត្ថិភាព។

ក្រសួងស្ថាប័ន និងអង្គការដៃគូ ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៦.បន្តចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីធានាប្រសិទ្ធភាពនៃការផ្ដល់សេវាជូនជនរងគ្រោះ ។

៧.ពិនិត្យលទ្ធភាព ដើម្បីបង្កើតមជ្ឈមណ្ឌលស្ដារនីតិសម្បទាជនរងគ្រោះជារបស់រដ្ឋ។

៨.គាំទ្រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្ដុះបណ្ដាលមន្ត្រីពាក់ព័ន្ធនៅ ក្នុងស្ថាន តំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសគោលដៅ អំពីគោលការណ៍ណែនាំ ស្ដីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប។

៩.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងមានការគាំទ្រពីអង្គការ JICA ធ្វើការសិក្សា វាយតម្លៃ និងធ្វើបច្ចុប្បន្នភាព លើគោលការណ៍ណែនាំ ស្ដីពី«ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្ដល់សេវាសមស្រប» និងរៀបចំនីតិវិធី ប្រព័ន្ធបញ្ជូនថ្នាក់ជាតិ ។

១០.រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការផ្ដល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍។

**ង. ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ**

១.បន្តពង្រឹងយន្តការដឹកនាំបញ្ជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពទាំងលើការងារផ្សព្វផ្សាយអប់រំ និងការចាត់តាំងអនុវត្តច្បាប់ ព្រមទាំងជំរុញការតាមដានត្រួតពិនិត្យ និងកែលម្អជាប្រចាំចំពោះកិច្ចប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់សំដៅជំរុញឱ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាន់តែទទួលបានប្រសិទ្ធផលខ្ពស់។

២.ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តន៍ថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន ការងាររបាយការណ៍ ការកសាងផែនការ និងការងារត្រួតពិនិត្យ វាយតម្លៃ។

៣.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពង្រឹងការប្រមូលទិន្នន័យ ថ្នាក់ជាតិ ពាក់ព័ន្ធការងារបង្ការទប់ស្កាត់ ការអនុវត្តច្បាប់ ការផ្តន្ទាទោស និងកិច្ចការពារជនរងគ្រោះឱ្យមានសង្គតិភាព។

៤.ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗ ដល់មន្ត្រីជំនាញក្នុងក្រុមការងារអន្តរក្រសួង ស្ថាប័ន និងលេខាធិការដ្ឋានរាជធានី ខេត្ត ។

៥.បន្តធ្វើសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការ រាជធានី ខេត្ត។

៦.ប្រកាសផ្សព្វផ្សាយ ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០២៤-២០២៨ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញឲ្យមានផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់ ក្រសួង ស្ថាប័ន ក្រុមការងារអន្តរក្រសួង ស្ថាប័ន និងរាជធានីខេត្ត ដើម្បីអនុវត្ត ។

៧.ពង្រឹងការងារតាមដាន ត្រួតពិនិត្យ

ថ្ងៃ ពុធ ១៣ កើត ខែ ផល្គុន ឆ្នាំ រោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២៤

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ គ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ